ធនាគារអភិវឌ្ឍន៍អាស៊ី

# របាយការណ៍ត្រួតពិនិត្យ និងវាយតម្លៃ
# របស់អ្នកសម្របសម្រួលគម្រោងពិសេស
# អំពី
# គម្រោងភ្ជាប់ក្រុងភ្នំពេញ ទៅក្រុងហូជីមិញ
# ប្រទេសកម្ពុជា

**ធនាគារអភិវឌ្ឍន៍អាស៊ី កម្ចីលេខ ១៦៥៩-CAM (SF) ( ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៨)**



ខែតុលា ឆ្នាំ២០០៧

ឯកសារនេះត្រូវបានបកប្រែចេញពីអត្ថបទជាភាសាអង់គ្លេស មកជាភាសាខ្មែរ ។ អត្ថបទជាភាសាអង់គ្លេសគឺជាអត្ថបទផ្លូវការរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ហើយមានតែអត្ថបទដើមជាភាសាអង់គ្លេសប៉ុណ្ណោះដែលមានលក្ខណៈយថាភូត អាចយោង ឬធ្វើជាសំអាងផ្លូវការបាន ។ រាល់ការធ្វើសេចក្តីយោងលើអត្ថបទនេះ ចាំបាច់ត្រូវយោងទៅលើអត្ថបទដើមជាភាសាអង់គ្លេស ។ ធនាគារអភិវឌ្ឍន៍អាស៊ី មិនធានាខុសត្រូវចំពោះភាពសុក្រឹត្យត្រឹមត្រូវនៃការបកប្រែជាភាសាខ្មែរ ហើយក៏មិនទទួលខុសត្រូវចំពោះចំនុចដែលអាចមានអត្ថន័យខុសពីខ្លឹមសារនៃអត្ថបទដើមឡើយ ។

# អក្សរកាត់

| | |
|---|---|
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី (អេ.ឌី.ប៊ី) |
| AP | ជនរងផលប៉ះពាល់ |
| CARM | និវាសនដ្ឋានបេសកកម្មប្រចាំប្រទេសកម្ពុជា (នៃធនាគារអភិវឌ្ឍន៍អាស៊ី) |
| CDCam | អង្គការអភិរក្ស និងអភិវឌ្ឍន៍កម្ពុជា (អង្គការមិនមែនរដ្ឋាភិបាល) |
| GMS | មហាអនុតំបន់ទន្លេមេគង្គ |
| IRC | គណៈកម្មការអន្តរក្រសួងសម្រាប់ដោះស្រាយផលប៉ះពាល់ដោយសារគម្រោង |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NR | ផ្លូវជាតិ |
| OSPF | ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស (អូ.អេស.ភី.អែហ្វ) |
| RAR | របាយការណ៍ត្រួតពិនិត្យ និងវាយតម្លៃ |
| TA | ជំនួយបច្ចេកទេស |

# បញ្ជីមាតិកា

ទំព័រ

**អក្សរកាត់** ------------------------------------------------------------ ii

**សេចក្តីសង្ខេបប្រតិបត្តិ** ------------------------------------------------------ ivវ

**ផែនទី**------------------------------------------------------------ ១

**១. សាវតារ** ------------------------------------------------------------ ២

ក. គម្រោង ------------------------------------------------------------ ២

ខ. បណ្តឹងតវ៉ា ------------------------------------------------------------ ៥

គ. ការកំណត់លក្ខណៈសម្បត្តិ ------------------------------------------------------------ ៧

**២. ការត្រួតពិនិត្យ និងវាយតម្លៃ** ------------------------------------------------------------ ៩

ក. គោលបំណង និងវិធីសាស្ត្រ ------------------------------------------------------------ ៩

ខ. ការកំណត់អ្នកពាក់ព័ន្ធ ------------------------------------------------------------ ១០

គ. ការកំណត់អត្តសញ្ញាណបញ្ហានៃបណ្តឹង ------------------------------------------------------------ ១៤

ឃ. ការវាយតម្លៃលើក៏រិតលទ្ធភាពដោះស្រាយបញ្ហា ------------------------------------------------------------ ១៦

**៣. អនុសាសន៍ និងសំណើវិធានការសកម្មភាពដែលគួរអនុវត្ត** ------------------------------------------------------------ ១៦

ក. សកម្មភាពដំណោះស្រាយ និងអនុសាសន៍ ------------------------------------------------------------ ១៦

ខ. សំណើវិធានការសកម្មភាពដែលគួរអនុវត្ត ------------------------------------------------------------ ១៧

**ជំហាននានានៃដំណើរការពិគ្រោះយោបល់** ------------------------------------------------------------ ២០

ដំណើរការពិគ្រោះយោបល់ និងតារាងពេលវេលា------------------------------------------------------------ ២៣

គំរូនៃវិធានផ្ទៃក្នុងសម្រាប់ការប្រជុំពិភាក្សា ------------------------------------------------------------ ២៦

# សេចក្តីសង្ខេបប្រតិបត្តិ

គម្រោងផ្លូវជាតិពីក្រុងភ្នំពេញ ទៅក្រុងហូជីមិញ ជាផ្នែកមួយនៃគម្រោង**មហាអនុតំបន់ទន្លេមេគង្គ** ដែលរួមមានកម្ចីមួយសម្រាប់ប្រទេសកម្ពុជា និង កម្ចីមួយទៀតសម្រាប់ប្រទេសវៀតណាម។ កម្ចីនេះមានបំណងជួយសម្រួលដល់លំហូរចរាចរ និងពាណិជ្ជកម្ម រវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម តាមរយៈការជួយស្តារឡើងវិញនូវគម្រោងផ្លូវថ្នល់ និងរចនាសម្ព័ន្ធផ្សេងៗនៅតាមច្រកព្រំដែន។ ចំពោះកម្ចីរបស់ប្រទេសកម្ពុជា គឺ សម្រាប់ការស្តារឡើងវិញ និងពង្រីកបន្ថែមផ្លូវជាតិលេខ១ (NR1) ចាប់ពីផ្នែកខាងកើតនៃទន្លេមេគង្គ នៅកំពង់ចម្លងសាឡាងអ្នកលឿង រហូតដល់បាវិតជាប់ព្រំប្រទល់ប្រទេសវៀតណាម ដែលមានចម្ងាយ ១០៥ គីឡូម៉ែត្រ។ កម្ចីរបស់កម្ពុជា ត្រូវបានអនុម័ត កាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៨ ហើយកម្ចីនេះចាប់ផ្តើមអនុវត្តកាលពីថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៩៩។ តាមរយៈ សកម្មភាពសាងសង់ និងពង្រីកផ្លូវថ្នល់នេះ ប្រជាពលរដ្ឋមួយចំនួន ចាំបាច់ត្រូវផ្លាស់ប្តូរទីតាំង ហើយ ផែនការស្តីពីការដោះស្រាយផលប៉ះពាល់មួយត្រូវបានរៀបចំឡើង។ កាលពីឆ្នាំ២០០២ អង្គការមិនមែនរដ្ឋាភិបាលចំនួន២ បានដាក់របាយការណ៍មួយឱ្យធនាគារអភិវឌ្ឍន៍អាស៊ី (ADB = (អេ.ឌី.ប៊ី) ដោយអះអាងថា គ្រួសារដែលត្រូវបានផ្លាស់ប្តូរទីតាំងមួយចំនួនមិនបានទទួលសំណងគ្រប់គ្រាន់ទេ ហើយរបាយការណ៍នោះ បានលើកឡើងនូវចំនុចមួយចំនួនក្នុង ផែនការស្តីពីការដោះស្រាយផលប៉ះពាល់(RRP) និងកិច្ចព្រមព្រៀងស្តីពីការផ្តល់ប្រាក់កម្ចី ដោយចោទប្រកាន់ថាមិនត្រូវបានគោរពអនុវត្តតាមឡើយ។ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានស្នើឱ្យមានការធ្វើសវនកម្មឯករាជ្យលើការដោះស្រាយផលប៉ះពាល់ដោយសារគម្រោងនោះ ដើម្បីអង្កេតស្រាវជ្រាវ និងផ្តល់អនុសាសន៍ អំពីសកម្មភាពដោះស្រាយបញ្ហាទាំងឡាយដែលមិនទាន់បានស្រាយរួច។ សវនកម្មឯករាជ្យនោះបានធ្វើឡើងក្នុងអំឡុងពេលរវាងខែវិច្ឆិកា ឆ្នាំ២០០៤ និង ខែមីនា ឆ្នាំ២០០៥ ហើយរបាយការណ៍សវនកម្មនោះបានផ្តល់អនុសាសន៍អំពីផែនការសកម្មភាពដែលត្រូវអនុវត្ត ដែលក្នុងនោះរួមមានការផ្តល់សំណងនិងជំនួយនានាដែលមិនទាន់សងឬផ្តល់ជូនដល់ជនរងផលប៉ះពាល់ដែលមានលក្ខណៈសម្បត្តិទទួលបាន (APs) ។ រដ្ឋាភិបាលកម្ពុជា និង ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានខិតខំប្រឹងប្រែងជាច្រើន ដើម្បីធ្វើឱ្យប្រាកដថា ជនរងផលប៉ះពាល់ (APs) ទទួលបានសំណង បន្ថែមទៀតនូវចំនួនដែលមិនទាន់បានផ្តល់ឱ្យជនរងផលប៉ះពាល់ ដោយផ្អែកតាមការរកឃើញរបស់សវនកម្មឯករាជ្យ ហើយការបង់សំណងបន្ថែមទៀតនោះ ត្រូវធ្វើឡើងក្នុងអំឡុងឆ្នាំ២០០៥ និង២០០៦។ ករណីរបស់ជនរងផលប៉ះពាល់មួយចំនួន ដែលបានប្តឹងថាខ្លួនមិនទាន់បានទទួលសំណងគ្រប់គ្រាន់ កំពុងស្ថិតក្នុង ដំណើរការអង្កេតស្រាវជ្រាវឱ្យបានច្បាស់លាស់។

កាលពីថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧ ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស (OSPF = អូ.អេស.ភី.អែហ្វ) បានទទួលពាក្យបណ្តឹងចំនួន២ មកពីជនរងផលប៉ះពាល់សរុបចំនួន៦៣ នាក់ រស់នៅក្នុងសហគមន៍ក្រាំងក្អុក និងស្ទឹងស្លួត ខេត្តស្វាយរៀង។ ពាក្យបណ្តឹងនោះបានយោងទៅសវនកម្មឯករាជ្យដែលបានធ្វើកន្លងមក ប៉ុន្តែបាននិយាយថា បញ្ហារបស់ជនរងផលប៉ះពាល់ (APs) នៅមិនទាន់ត្រូវបានដោះស្រាយទេ ហើយថា ជនរងផលប៉ះពាល់ទាំងនោះជាជនក្រីក្រ បានបាត់បង់ប្រភពចិញ្ចឹមជីវិត ហើយកំពុងរស់នៅក្នុងស្ថានភាពជំពាក់បំណុលគេយ៉ាងធ្ងន់ធ្ងរ។ ជនរងផលប៉ះពាល់ទាំងនោះបានស្នើ

សុំជំនួយថវិកាបន្ថែម សុំប័ណ្ណកម្មសិទ្ធិលើដីធ្លី សុំឱ្យមានគម្រោងបង្កើតការងារ និងសុំឱ្យធ្វើការអង្កេតស្រាវជ្រាវលើគ្រួសារដែលរងផលប៉ះពាល់ទាំងឡាយ ។ ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស (OSPF) បានធ្វើការត្រួតពិនិត្យ និងវាយតម្លៃពីកង្វល់ទាំងនោះ ហើយបានរកឃើញបញ្ហាពីរធំៗ គឺ បញ្ហាប័ណ្ណកម្មសិទ្ធិដី និងភាពកាន់ចុះដុនដាប ។ បញ្ហាទាំងនេះត្រូវបានលើកឡើង និងពិភាក្សាជាច្រើនឆ្នាំមកហើយ ប៉ុន្តែរហូតមកដល់ពេលបច្ចុប្បន្ននេះ គឺនៅតែមិនទាន់បានដោះស្រាយនៅឡើយ ។ ជនដែលជាម្ចាស់បណ្តឹងមានអារម្មណ៍យ៉ាងមុតមាំថា ពួកគាត់មានជីវភាពដុនដាបជាងមុនពេលមានគម្រោង ហើយថាពួកគាត់គួរណាស់ទទួលបានជំនួយបន្ថែមទៀត ក្រៅពីសំណងដែលបានសងតាមលទ្ធផលនៃសវនកម្ម ។

រដ្ឋាភិបាលកម្ពុជា និង និវាសនដ្ឋានបេសសកម្មប្រចាំប្រទេសកម្ពុជា (CARM) បានធ្វើការយកចិត្តទុកដាក់យ៉ាងខ្លាំងពីបញ្ហានេះ ដោយចាប់ផ្តើមពីការធ្វើសវនកម្មឯករាជ្យ ហើយបានកំពុងផ្តោតចិត្តទុកដាក់លើកិច្ចខិតខំប្រឹងប្រែងទាំងនោះ។ អង្គការមិនមែនរដ្ឋាភិបាល បានធ្វើការចាប់អារម្មណ៍លើបញ្ហាដោះស្រាយផលប៉ះពាល់ដោយគម្រោងនេះអស់ពេលជាច្រើនឆ្នាំមកហើយដែរ ហើយមានអង្គការមួយ ហៅថាអង្គការអភិរក្ស និងអភិវឌ្ឍន៏កម្ពុជា (CDCam) ដែលតំបូងឡើងបានដើរតួនាទីជាច្រកទំនាក់ទំនងជាមួយដើមបណ្តឹងសម្រាប់ករណីបណ្តឹងនេះ ។ ប៉ុន្តែនាពេលថ្មីៗនេះ ដើមបណ្តឹងបានប្រគល់សិទ្ធិឱ្យអង្គការអភិរក្ស និងអភិវឌ្ឍន៏កម្ពុជា (CDCam) ធ្វើជាតំណាងរបស់ខ្លួន ។ ការដោះស្រាយបណ្តឹងតាមរយៈដំណើរការពិគ្រោះយោបល់ នឹងតម្រូវឱ្យមានការប្តេជ្ញាចិត្តពីសំណាក់អ្នកពាក់ព័ន្ធទាំងអស់ក្នុងការរកដំណោះស្រាយ ។

ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស(OSPF)ស្នើថា ដំណើរការពិគ្រោះយោបល់ គួរតែរៀបចំធ្វើឡើង ហើយដំណាក់កាលបន្ទាប់គឺការចែករបាយណ៍ត្រួតពិនិត្យ និងវាយតម្លៃនេះ ជូនដល់ជនរងផលប៉ះពាល់ដែលជាដើមបណ្តឹង និងជូនដល់ និវាសនដ្ឋានបេសសកម្មប្រចាំកម្ពុជា (CARM) ។ ដំណាក់កាលបន្ទាប់ទៀតគឺការសម្រេចចិត្តរបស់ជនរងផលប៉ះពាល់ដែលជាដើមបណ្តឹងថាតើចង់បន្តដំណើរការពិគ្រោះយោបល់ទៀត ឬ យ៉ាងណា ។ ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស(OSPF) នឹងផ្តល់ឱ្យដើមបណ្តឹងនូវជំនួយជាទីប្រឹក្សាឯករាជ្យម្នាក់សម្រាប់ជួយឱ្យពួកគាត់អាចយល់បានច្បាស់អំពីខ្លឹមសារនៃរបាយការណ៍នេះ ដោយឆ្លើយសំណួរនានាដែលអាចលើកឡើងដោយជនរងផលប៉ះពាល់នោះ ធ្វើការស្រាយបំភ្លឺលើចំនុចពាក់ព័ន្ធនានា និងផ្តល់យោបល់ប្រឹក្សាអព្យាក្រឹតស្តីពីផលវិបាកនៃការសម្រេចចិត្តរបស់ជនរងផលប៉ះពាល់ ។ ប្រសិនបើដើមបណ្តឹង សម្រេចចិត្តបន្តដំណើរការពិគ្រោះយោបល់ ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស នឹងស្នើឱ្យដើមបណ្តឹង និង និវាសនដ្ឋានបេសសកម្មប្រចាំកម្ពុជា (CARM) ផ្តល់មតិយោបល់លើខ្លឹមសារនៃការរកឃើញដែលបានរៀបចំក្នុងរបាយការណ៍នេះ ។ ទីប្រឹក្សាឯករាជ្យ នឹងជួយដើមបណ្តឹងរៀបចំសរសេរមតិយោបល់របស់ដើមបណ្តឹង ។ ផ្អែកលើការឆ្លើយតបនានាដែលអាចនឹងទទួលបាន ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស(OSPF)នឹងធ្វើការវាយតម្លៃឡើងវិញលើក៏រិតលទ្ធភាពជោគជ័យនៃដំណើរការពិគ្រោះយោបល់ និងផ្តល់អនុសាសន៍ទៅឱ្យ ប្រធាននៃធនាគារអភិវឌ្ឍន៏អាស៊ី(ADB) ថាគួរបន្តនីតិវិធីសប្រមសម្រួល និងដាក់ចេញនូវវិធានការសកម្មភាព តាមរយៈ ការពិគ្រោះយោបល់ជាមួយជនរងផលប៉ះពាល់ដែលជាដើមបណ្តឹង និវាសនដ្ឋានបេសសកម្មប្រចាំកម្ពុជា(CARM) និង ជាមួយរដ្ឋាភិបាលកម្ពុជា

ឬ គួរបញ្ចប់ដំណើរការពិគ្រោះយោបល់នេះដោយហេតុថានឹងគ្មានប្រយោជន៍ក្នុងការត្រួតពិនិត្យ ឡើងវិញទៀតឡើយ។ ប្រសិនបើមានការសម្រេចចិត្ត ថាចង់បន្តដំណើរការពិគ្រោះយោបល់ ក្នុងករណីនោះ នឹងមាន ការរៀបចំកិច្ចប្រជុំជាច្រើនហូរហែរជាមួយអ្នកពាក់ព័ន្ធទាំងអស់ ដើម្បីជួយធ្វើឱ្យអ្នកពាក់ព័ន្ធទាំងនោះអាចឈានដល់ការ ឯកភាពព្រមព្រៀងគ្នាស្តីពីរបៀបដោះស្រាយបញ្ហាដែលលើកឡើងដោយដើមបណ្តឹង។ កិច្ចប្រជុំជាហូរហែរនោះនឹងមាន ការសម្របសម្រួលដោយការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស (OSPF) ឬ ដោយអ្នកសម្របសម្រួលផ្សេង ទៀតដែលអ្នកពាក់ព័ន្ធអាចទទួលយកបាន។ អ្នកសម្របសម្រួលនឹងធ្វើផែនការសម្រាប់កិច្ចប្រជុំ ដោយមានការចូលរួមពី សំណាក់អ្នកពាក់ព័ន្ធផងដែររួចធ្វើការរៀបចំ និងសម្របសម្រួលកិច្ចប្រជុំពិភាក្សារកដំណោះស្រាយនោះ។

# ផែនទី


104°00'E
107°00'E
CAMBODIA AND VIET NAM
GREATER MEKONG SUBREGION:
PHNOM PENH TO HO CHI MINH CITY HIGHWAY PROJECT
Tonle Sap
Kompong Thom
Pursat
Kratie
Mekong River
Kompong Chhnang
Snoul
Kompong Cham
B. Dang Krien
Binh Long
CAMBODIA
PHNOM PENH
Prey Veng
Bao Luc
Tay Ninh
Chon Thanh
Kompong Speu
Kompong Trabec
Noek Loeung
Dong Sai
Sre Ambel
Svay Rieng
Moc Bai
Go Dau
Thu Dau Mot
Takeo
Bavet
Bien Hoa
Chau Phu
An Suong
Thu Duc
Veal Renh
Cho Lon
HO CHI MINH CITY (SAIGON)
Sihanoukville
Kampot
VIET NAM
Kep
Tan An
Phuoc Leo
Ha Tien
My Tho
Vung Tau
Long Xuyen
Duong Dong
Hon Chong
Vinh Long
Rach Gia
Can Tho
South China Sea
Ba Dong
Soc Trang
Khanh Hung
Gulf of Thailand
Mouth of Mekong
Ca Mau
Bac Lieu
Quan Long
Nam Can
12°30'N
9°00'N
N
0 10 20 30 40 50 100
Kilometers
National Capital
Provincial Capital
City/Town
Airport
Project Road
Main Road
Secondary Road
Railway
River
International Boundary
Boundaries are not necessarily authoritative.
07-3595 HR

# ១. សារតារ

## ក. គម្រោង

១. គម្រោងផ្លូវជាតិ ពីក្រុងភ្នំពេញ ទៅក្រុងហូជីមិញ ដែលជាផ្នែកមួយនៃគម្រោងមហាអនុតំបន់ទន្លេមេគង្គ បានអនុម័តដោយក្រុមប្រឹក្សានាយករបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) កាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៨។ គម្រោងកម្ចីឥណទាននេះមានពីរកញ្ចប់ គឺ មួយកញ្ចប់សម្រាប់ប្រទេសកម្ពុជា (កម្ចីលេខ ១៦៥៩-CAM(SF)) និងមួយកញ្ចប់ទៀតសម្រាប់ប្រទេសវៀតណាម (កម្ចីលេខ ១៦៦០-VIE(SF))។ គម្រោងនេះជាគម្រោងទីមួយដែលបានរៀបចំឡើងក្រោមគំនិតផ្តួចផ្តើមរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) សម្រាប់មហាអនុតំបន់ទន្លេមេគង្គ ហើយគម្រោងនេះមានគោលបំណង ជួយសម្រួលដល់លំហូរចរាចរ និងពាណិជ្ជកម្ម រវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម តាមរយៈការកែលំអគម្រោងផ្លូវថ្នល់ និងរចនាសម្ព័ន្ធផ្សេងទៀត។នៅច្រកព្រំដែន និង ជួយឱ្យមានបរិយាកាសងាយស្រួលក្នុងការធ្វើពាណិជ្ជកម្មឆ្លងដែនតាមរយៈការកាត់បន្ថយការិយាធិបតេយ្យ និងនិតិវិធីស្មុគ្រស្មាញទាំងឡាយដែលជាឧបសគ្គសម្រាប់ពាណិជ្ជកម្មឆ្លងដែន។ កញ្ចប់ថវិការសម្រាប់សមាសធាតុនៃគម្រោងនៅក្នុងប្រទេសកម្ពុជាមានទឹកប្រាក់សរុប ៥០,៧ លានដុល្លា ដែលក្នុងនោះ រួមទាំងកម្ចីពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ប្រមាណជា ៤០លានដុល្លា ស្មើនឹង ២៨.៤០២.000 ដុល្លាស្តង់ដារ(SDR) សម្រាប់ការពង្រីក និងស្តារផ្លូវជាតិលេខ១ ចំងាយ១០៥គ.ម ឡើងវិញ ដោយគិតចាប់ពីត្រើយកើតនៃទន្លេមេគង្គនៅកំពង់ចម្លងសាឡាងអ្នកលឿង (ឆ្លងកាត់តំបន់ដែល មិនសូវមានប្រជាពលរដ្ឋរស់នៅ និងវាលស្រែនៅក្នុងឃុំមួយចំនួននៃខេត្តស្វាយរៀងទៅកាន់បាវិតនៅច្រកព្រំដែនជាមួយប្រទេសវៀតណាម។ កម្ចីនេះ ក៏សម្រាប់ការស្តារឡើងវិញ ឬ កសាងនូវស្ពាន និងសំណង់សម្រាប់គយ និង ការិយាល័យអន្តោប្រវេសន៍ព្រមទាំងគ្រឿងបរិក្ខារផ្សេង។នៅផ្នែកខាងព្រំដែនរបស់កម្ពុជា (សូមមើលផែនទី)។ ក្រៅពីនេះ នៅក្នុងគម្រោងនេះក៏មានបញ្ចូលថវិកាសម្រាប់ការស្តារឡើងវិញនូវផ្លូវចម្ងាយ៦០គ.ម ពីភ្នំពេញទៅកាន់កំពង់ចម្លងសាឡាងអ្នកលឿងនៃទន្លេមេគង្គ ថវិកាសម្រាប់សេវាទីប្រឹក្សាបច្ចេកទេស ដែលក្នុងនោះរួមមាន ការតាមដានលើការដោះស្រាយផលប៉ះពាល់ និងការធ្វើលទ្ធកម្មដីធ្លី និង កិច្ចការផ្សេងទៀត។ គម្រោងនេះ ចាប់ផ្តើមមានប្រសិទ្ធភាពអនុវត នៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ហើយបញ្ចប់ការអនុវត្តនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៦។ ក្រសួងសាធារណការ និងដឹកជញ្ជូន ជាភ្នាក់ងារប្រតិបត្តិគម្រោង។

២. ផែនការស្តីពីការដោះស្រាយផលប៉ះពាល់(RRP)សម្រាប់គម្រោងនេះមានចែងថា "... គម្រោងនេះនឹងតម្រូវឱ្យមានការដោះស្រាយផលប៉ះពាល់ និង ការផ្លាស់ទីប្រជាពលរដ្ឋ តែមួយចំនួនតូច ដោយសារគម្រោងផ្លូវ គឺធ្វើឡើងតាមផ្លូវចាស់ លើកលែងតែកំណាត់ផ្លូវខ្លី១មួយចំនួនដែលត្រូវត្រួសត្រាយគន្លងថ្មីដើម្បីបញ្ចៀសតំបន់ដែលមានមនុស្សរស់នៅច្រើន។ ក្នុងផែនការស្តីពីការដោះស្រាយផលប៉ះពាល់(RRP) មានបន្ថែមតារាងឧបសម្ព័ន្ធស្តីពី "ផែនការសង្ខេប

នៃដោះស្រាយផលប៉ះពាល់គម្រោង សម្រាប់សមាសធាតុក្នុងប្រទេសកម្ពុជា (SRAP)" ដែលជា ផែនការសង្ខេបខ្លីៗ បានពីផែនការសកម្មភាពសម្រាប់ការដោះស្រាយផលប៉ះពាល់ និង ស្តារលទ្ធភាពចិញ្ចឹមជីវិត ដែលរៀបចំដោយទីប្រឹក្សាក្រោមជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។ ការរៀបចំផែនការសង្ខេបនេះ គឺជាលក្ខខណ្ឌតម្រូវឱ្យមានមុនមានការពិនិត្យវាយតម្លៃសំណើគម្រោង។ ក្នុងផែនការសង្ខេបនៃការដោះស្រាយផលប៉ះពាល់គម្រោង (SRAP) បានបង្ហាញថាគម្រោងនឹងត្រូវការធ្វើលទ្ធកម្មដីប្រហែល ២១០ ហិកតា ទំនងប៉ះពាល់ប្រជាពលរដ្ឋ ៥.៩២០ នាក់ ដែលរស់នៅក្នុងទីតាំងជំរក ១.១៨៤កន្លែង និង បង្ហាញទៀតថា "ភាគច្រើននៃទីតាំងជំរក(ផ្ទះសំបែង និងសំណង់ផ្សេងៗ) ទាំងនោះអាចត្រូវរងការប៉ះពាល់តែមួយចំណែកប៉ុណ្ណោះ ហើយមានទីតាំងជំរកតែមួយចំនួនតូចដែលត្រូវផ្លាស់ប្តូរទីតាំង"។ ផែនការសង្ខេបនៃដោះស្រាយផលប៉ះពាល់គម្រោង (SRAP) បានបង្ហាញទៀតថា "ការចុះពិនិត្យទីតាំង ដែលបានធ្វើនាពេលក្រោយមកទៀត បានបង្ហាញថាចំនួនតួលេខទាំងនេះ ជាពិសេសគឺចំនួនផ្ទះសំបែង និងសំណង់ផ្សេងៗ និងចំនួនប្រជាពលរដ្ឋ ត្រូវបានប៉ាន់ស្មានលើសពីចំនួនពិត"។ ប្រសិទ្ធភាពនៃកម្ចីត្រូវបានពន្យារពេលដោយមូលហេតុផ្សេងៗ ដែលក្នុងនោះរួមមាន តម្រូវការឱ្យមានការកែសម្រួលឡើងវិញនូវផែនការសម្រាប់អនុវត្តការដោះស្រាយផលប៉ះពាល់ ដើម្បីឆ្លើយតបនឹងលក្ខខណ្ឌតម្រូវរបស់ធនាគារអភិវឌ្ឍន៍អាស៊ី(ADB)។ ការធ្វើផែនការ និងការអនុវត្តនូវការដោះស្រាយផលប៉ះពាល់ដោយសារគម្រោងនេះ ត្រូវបានដឹកនាំដោយគណៈកម្មការអន្តរក្រសួងសម្រាប់ដោះស្រាយផលប៉ះពាល់គម្រោង(IRC) ដោយមាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ[១] ជាប្រធាន ដែលមិនមែនដឹកនាំដោយភ្នាក់ងារប្រតិបត្តិគម្រោងទេ។

៣. នៅឆ្នាំ២០០២ មានអង្គការមិនមែនរដ្ឋាភិបាលចំនួន២បានដាក់របាយការណ៍មកធនាគាអភិវឌ្ឍន៍អាស៊ី(ADB) ជំនួសមុខឱ្យ ៩៩គ្រួសារ ដែលរស់នៅតាមបណ្តោយផ្លូវនោះ ក្នុងខេត្តព្រៃវែង។ ក្នុងរបាយការណ៍នោះបានលើកឡើងថា គ្រួសារទាំងនោះមិនបានទទួលសំណងគ្រប់គ្រាន់ទេ ហើយក៏បានលើកឡើងនូវ ចំនុចមួយចំនួនក្នុងផែនការស្តីពីការដោះស្រាយផលប៉ះពាល់(RRP) និងកិច្ចព្រមព្រៀងស្តីពីការផ្តល់ប្រាក់កម្ចី ដោយចោទប្រកាន់ថាមិនត្រូវបានគោរពអនុវត្តតាម។ ក្រុមបេសកកម្មរបស់ធនាគារអភិវឌ្ឍន៍អាស៊ី បានចុះមកធ្វើការវាយតម្លៃលើការដោះស្រាយផលប៉ះពាល់ កាលពីខែមិថុនា ឆ្នាំ២០០២ ហើយរកឃើញថា ការចោទប្រកាន់របស់អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនពិតជា

---

[១] គណៈកម្មការអន្តរក្រសួងសម្រាប់ការដោះស្រាយផលប៉ះពាល់គម្រោង (IRC) បានបង្កើតឡើងនៅឆ្នាំ ១៩៩៨ ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ។ សមាជិកផ្សេងទៀតរបស់គណៈកម្មការអន្តរក្រសួងនេះមានតំណាងមកពី ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខុទ្ទិកាល័យសាលាក្រុងភ្នំពេញ អភិបាល និងអភិបាលរងខេត្តព្រៃវែង និងខេត្តស្វាយរៀង។

មានមូលដ្ឋានត្រឹមត្រូវ ហើយក្រុមបេសសកម្មវាយតម្លៃនោះបានស្នើឱ្យមានសវនកម្មឯករាជ្យលើការដោះស្រាយផលប៉ះពាល់នោះ សម្រាប់ធ្វើការអង្កេតស្រាវជ្រាវ រួចផ្ដល់អនុសាសន៍អំពីវិធានការសកម្មភាពបន្ថែមទៀត សម្រាប់ដោះស្រាយបញ្ហានានាដែលនៅសល់។ រដ្ឋាភិបាលកម្ពុជាមិនយល់ព្រមឱ្យមានការធ្វើសវនកម្មទេ ប៉ុន្តែបានធ្វើការប្ដេជ្ញាថានឹងចាត់វិធានការដោះស្រាយរាល់បណ្ដឹងទាំងអស់។ ប៉ុន្តែទោះជាមានការប្ដេជ្ញានោះក៏ដោយ ក៏បញ្ហាមួយចំនួននៅតែបន្តមាន ហើយនៅឆ្នាំ២០០៤ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានស្នើសារជាថ្មីម្ដងទៀតឱ្យមានការធ្វើសវនកម្មលើការដោះស្រាយផលប៉ះពាល់នោះ ហើយក្នុងពេលនោះ រដ្ឋាភិបាលកម្ពុជាបានយល់ព្រមឱ្យមានការធ្វើសវនកម្ម។ សវនកម្មលើការដោះស្រាយផលប៉ះពាល់ ធ្វើឡើងដោយអ្នកជំនាញការមួយក្រុម (និងត្រូវបានផ្ដល់ហិរញ្ញវត្ថុដោយគម្រោងបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB TA[2]) ដោយមានការចូលរួមពីសំណាក់សមាជិកគណៈកម្មការអន្តរក្រសួងសម្រាប់ការដោះស្រាយផលប៉ះពាល់គម្រោង (IRC) និង អង្គការវេទិកាមិនមែនរដ្ឋាភិបាលនៅកម្ពុជា (NGO Forum on Cambodia) ដែលបានចាប់ផ្ដើមធ្វើឡើងនៅខែវិច្ឆិកា ឆ្នាំ២០០៤ និងបញ្ចប់សេចក្ដីព្រាងរបាយការណ៍សេវនកម្ម កាលខែមិនា ឆ្នាំ២០០៥ ហើយសេចក្ដីព្រាងចុងក្រោយនៃរបាយការណ៍សវនកម្មនេះត្រូវបានបញ្ចប់នៅ ខែកក្កដា ឆ្នាំ២០០៥។ សវនកម្មនោះបានរកឃើញបញ្ហាចម្បងមួយចំនួន ហើយសន្និដានថា ជនរងផលប៉ះពាល់ (APs) ជាពិសេសអ្នកក្រីក្រ បានបន្តប្រឈមមុខនឹងភាពងាយរងគ្រោះដោយហានិភ័យមួយចំនួន។ សវនកម្មនោះបានផ្ដល់អនុសាសន៍ថា ផែនការសកម្មភាពមួយគួរត្រូវតែយកមកអនុវត្ត ដែលក្នុងនោះអាចមានជាការផ្ដល់សំណងប្រាក់ឧបត្ថម្ភ និង ការជួយក្នុងរូបភាពផ្សេងៗទៀតដែលមិនទាន់បានផ្ដល់ឱ្យជនរងផលប៉ះពាល់ដែលមានលក្ខណៈសម្បត្តិក្នុងទទួលបានសំណង ឬ ជំនួយនានា។ ការចំណាយសម្រាប់ការសងសំណង និងជំនួយនោះ គឺមានចំនួនតិចជាង ៦២៥,០០០ ដុល្លា តែប៉ុណ្ណោះ។ ចាប់តាំងពីបានធ្វើសវនកម្មមក កិច្ចខិតខំប្រឹងប្រែងមួយចំនួនត្រូវបានធ្វើឡើងដើម្បីធ្វើឱ្យប្រាកដថាជនរងផលប៉ះពាល់ (APs) ទទួលបានសំណងបន្ថែមដែលនៅជំពាក់ពួកគាត់ ដោយយោងទៅតាមការរកឃើញរបស់សវនកម្ម។ ការសងនូវទឹកប្រាក់ខាងលើ គឺធ្វើឡើងនៅឆ្នាំ២០០៥ និង២០០៦។ ទោះជាបានសងប្រាក់នោះហើយក៏ដោយ នៅចុងឆ្នាំ ២០០៦ អង្គការ វេទិកាអង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជា (NGO Forum on Cambodia) បានលើកឡើងពីបញ្ហាមួយចំនួនទៀតថា មានគ្រួសារមួយចំនួននៅមិនទាន់បានទទួលសំណងគ្រប់នៅឡើយ ហើយករណីសងមិនគ្រប់នេះ គឺកំពុងត្រូវបានពិភាក្សា។ អង្គការ វេទិកាអង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជា (NGO Forum on Cambodia) បានស្នើសុំពេលវេលាបន្ថែមដើម្បីចងក្រងឯកសារនូវករណីទាំងនេះ។ នៅពេល

---

២. TA No. 6091-REG ជំនួយបច្ចេកទេសសម្រាប់ការកសាងសមត្ថភាពសម្រាប់ការគ្រប់គ្រងហានិភ័យលើការដោះស្រាយផលប៉ះពាល់ដែលទទួលបានការអនុម័តយល់ព្រមនៅ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០២។

ប្រាក់សំណងទាំងឡាយដែលជំពាក់នោះត្រូវបានបង់សងរួចអស់ របាយការណ៍សវនកម្មចុងក្រោយ នឹងត្រូវបានផ្សព្វផ្សាយក្នុងគេហទំព័ររបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ។ ជាការឆ្លើយតបនឹងសំណូមពររបស់អង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ធនាគារអភិវឌ្ឍន៍អាស៊ី បានយល់ព្រមថា របាយការណ៍បញ្ចប់គម្រោង នឹងចាប់ផ្តើមដំណើរការដរាបណាសកម្មភាពសវនកម្ម ត្រូវបានធ្វើឡើងចប់សព្វគ្រប់ ប្រកបដោយការពេញចិត្ត។ ស្របគ្នាជាមួយនឹងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និង រដ្ឋាភិបាលកម្ពុជា អង្គការមិនមែនរដ្ឋាភិបាលទាំងឡាយក៏យល់ព្រមថា "...នឹងគ្មានករណីបណ្តឹងថ្មីណាទៀតនឹងត្រូវទទួលការដោះស្រាយឡើយ ដោយសារមានការផ្តល់ព័ត៌មាន និងឱកាសឱ្យប្រជាពលរដ្ឋដែលរស់នៅតាមបណ្តោយផ្លូវជាតិលេខ១គ្រប់គ្រាន់សម្រាប់ការដាក់បណ្តឹងតវ៉ារួចហើយ"។

## ខ. បណ្តឹងតវ៉ា

៤. នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧ ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស (OSPF) ទទួលបានបណ្តឹងចំនួន២ ជាភាសាខ្មែរ[៣] ទាក់ទងនឹងគម្រោង ដែលផ្ញើតាមអ៊ីម៉ែលក្នុងអត្ថបទភ្ជាប់អ៊ីមែលរបស់លោក សូត្រ សុផុន (ប្រធានស្តីទីរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយឈ្មោះថាអង្គការអភិរក្ស និងអភិវឌ្ឍកម្ពុជា (CDCam))។ លិខិតបណ្តឹងមួយច្បាប់ មានចុះហត្ថលេខារបស់ អ្នកស្រី ស៊ិន ឈិន ប្រធានសហគមន៍ក្រាំងក្អក នៅឃុំកំពុងសឿង ស្រុកព្រះស្តេច ខេត្តព្រៃវែង និងមានបញ្ជីឈ្មោះជនរងផលប៉ះពាល់ ៤១នាក់។ លិខិតបណ្តឹងមួយច្បាប់ផ្សេងទៀត មានចុះហត្ថលេខាដោយ អ្នកស្រី ប៉ែន វណ្ណា ប្រធានសហគមន៍ស្ទឹងស្លូត នៅឃុំអ្នកលឿង ស្រុកពាមរ ខេត្តព្រៃវែង ដោយមានបញ្ជីឈ្មោះអ្នករងផលប៉ះពាល់២២នាក់។ លិខិតបណ្តឹងទាំងពីរបានយោងទៅលើការធ្វើ សវនកម្មកន្លងមកនោះផងដែរ ប៉ុន្តែអះអាងថាបញ្ហារបស់ជនរងផលប៉ះពាល់ (APs) នៅមិនទាន់បានដោះស្រាយនៅឡើយ ហើយថាជនរងផលប៉ះពាល់ទាំងនោះ ជាអ្នកក្រីក្រ បានបាត់បង់មុខរបរចិញ្ចឹមជីវិត ហើយកំពុងជំពាក់បំណុលគេយ៉ាងធ្ងន់ធ្ងរ។ លិខិតទាំងពីរនេះ បានស្នើសុំឱ្យមានការផ្តល់ "ថវិកាបន្ថែមទៀត" ផ្តល់ប័ណ្ណកម្មសិទ្ធិលើដីធ្លី ដែលបានផ្តល់ឱ្យពួកខ្លួនជាកន្លែងផ្លាស់ប្តូរទីតាំង ផ្តល់"គម្រោងដែលបង្កើតការងារធ្វើ" និងបានសុំឱ្យការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស (OSPF) "ធ្វើការអង្កេតមួយ មិនត្រឹមតែសម្រាប់យើងទេ តែសម្រាប់គ្រួសារដែលរងផលប៉ះពាល់ទាំងអស់ដោយរាប់ទាំងអ្នកដែលរងផលប៉ះពាល់ហើយមិនទាន់ទទួលបានសំណងគ្រប់នៅឡើយ" ហើយថា ការិយាល័យ

---

[៣] សំបុត្រនេះផ្ញើជាភាសាខ្មែរ និងច្បាប់ថតចំលងជាភាសាអង់គ្លេស បានចុះក្នុងបញ្ជីពាក្យបណ្តឹង ដែលមានក្នុងវែបសៃត៍ : www.adb.org/spf. សំបុត្រជាភាសាខ្មែរ ក៏អាចរកឃើញតាមអស័យដ្ឋានវែបសៃត៍ដូចតទៅ : http://adb.org/Documents/Translations/Khmer/Krang-Khok-KH.pdf និង http://adb.org/Documents/ Translations/Khmer/Steung-Slot-KH.pdf. សំបុត្រជាភាសាអង់គ្លេស អាចរកឃើញផងដែរតាមអស័យដ្ឋានវែបសៃត៍ដូចតទៅ : http://adb.org/SPF/documents/Krang-Khok.pdf និង http://adb.org/SPF/documents/Steung-Sloth.pdf.

អ្នកសម្របសម្រួលគម្រោងពិសេស (OSPF) "ទទួលយកដំណើរការគម្រោងអភិវឌ្ឍតាមវិធីមួយ ដែលមិនធ្វើឱ្យប្រជាពលរដ្ឋរងផលប៉ះពាល់ទេ"។ អ្នកដាក់លិខិតបណ្តឹងទាំងនោះ ក៏បាននិយាយទៀតថា ពួកគាត់អាចដាក់ជូនឯកសារបន្ថែមទៀត។ លើសពីនេះទៀត លិខិតបណ្តឹងមកពីសហគមន៍ ក្រាំងក្អុក បានស្នើសុំឱ្យការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស "ជួយ ហែម ឈាយ ដែលមានអាយុ៦០ឆ្នាំ ជាសមាជិករបស់សហគមន៍យើងខ្ញុំ ដែលរងផលប៉ះពាល់ដោយគម្រោងសាងសង់ផ្លូវជាតិនេះ ព្រោះថាពេលនេះគាត់នៅមិនទាន់បានដីសម្រាប់ការផ្លាស់ប្តូរទីតាំងនៅឡើយ ហើយគាត់ និងគ្រួសារកំពុងរស់នៅលើចិញ្ចើមថ្នល់"។ លិខិតបណ្តឹងទាំងពីរបានប្រគល់សិទ្ធិឱ្យ លោក សូត្រ សុផុន មកពីអង្គការអភិរក្ស និងអភិវឌ្ឍកម្ពុជា (CDCam) ដើរតួជាអ្នកសម្រាប់ទំនាក់ទំនង និងបានស្នើថារាល់ការឆ្លើយតបត្រូវធ្វើឡើងទាំងភាសាខ្មែរ និងអង់គ្លេស។

៥. ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស (OSPF) បានឱ្យគេបកប្រែលិខិតទាំងពីជាភាសាអង់គ្លេស ហើយធ្វើការឆ្លើយតបជាភាសាអង់គ្លេស និងភាសាខ្មែរ កាលពីថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៧។ ការឆ្លើយតបនេះបានបញ្ជាក់ថាបានទទួលលិខិតបណ្តឹងរបស់ប្រជាពលរដ្ឋទាំងនោះ ហើយបញ្ជាក់ថា ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស នឹងចុះបញ្ជីពាក្យបណ្តឹងនោះ ហើយចាប់ដំណើរការសាកសួរដើម្បីកំណត់ថាបណ្តឹងនោះមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការពិចារណាក្នុងដំណាក់កាលពិគ្រោះយោបល់នៃយន្តការគណនេយ្យភាពរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដែរឬទេ។ ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស បានចុះបញ្ជីបណ្តឹងនោះកាលពីថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៧។ លិខិតឆ្លើយតបរបស់ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស បានព្យាយាមស្វែងរកការបញ្ជាក់អំពីទង្វើ ឬការខ្វះចន្លោះអាក់ខានមិនបានធ្វើរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដែលនាំឱ្យមានការខូចខាតដល់ជនរងផលប៉ះពាល់ និង អំពីជំហានទាំងឡាយដែលបានធ្វើឡើងដើម្បីស្វែងរកដំណោះស្រាយជាដំបូងចំពោះបញ្ហានោះជាមួយតំណាងរបស់ធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំនៅកម្ពុជា ឬ ហៅថានិវាសនដ្ឋានបេសសកម្មប្រចាំកម្ពុជា (CARM) ដែលជាអ្នកធ្វើអភិបាលកិច្ចលើគម្រោង។ លិខិតឆ្លើយតបនោះក៏បានព្យាយាមស្វែងរកការបញ្ជាក់អំពីពេលវេលាណាដែលការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស អាចសង្ឃឹមថានឹងទទួលបានឯកសារបន្ថែម ការសួរបញ្ជាក់ទៅអ្នកដាក់បណ្តឹងវិញថាតើចង់ឱ្យរក្សាការសម្ងាត់នូវអត្តសញ្ញាណរបស់ខ្លួនឬអត់ និង ថាតើអ្នកទាំងនោះអនុញ្ញាតឱ្យការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស ចេញផ្សាយព័ត៌មានក្នុងបណ្តឹងនោះជាសារធារណៈដែរឬទេ។

៦. នាថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៧ ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស បានទទួលឯកសារបន្ថែមដែលអ្នកបណ្តឹងសន្យាផ្តល់ឱ្យ ដែលក្នុងនោះមាន "សេចក្តីពន្យល់បន្ថែមទៀតផងដែរ"។ ឯកសារបន្ថែមទាំងអស់រួមមាន (i) បញ្ជីរៀបរាប់អំពីទង្វើ និងការអាក់ខានមិនបានធ្វើរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ii) តារាងរៀបរាប់

អំពីសិទ្ធិ និង ផលប្រយោជន៍នានារបស់ដើមបណ្ដឹងដែលកំពុងរងផលប៉ះពាល់ជាអវិជ្ជមាន ដោយមានរៀបរាប់ពីទុក្ខលំបាករបស់ជនរងផលប៉ះពាល់ ១៤នាក់ មកពីសហគមន៍ក្រាំងក្អុក និង ៩នាក់មកពី សហគមន៍ស្ទឹងស្លូត (iii) ឧបសគ្គភាពដែលជនរងផលប៉ះពាល់បានប្រឹងប្រែងដោយសុចរិតក្នុងការស្វែងរកដោះស្រាយជាមួយ "គណៈគ្រប់គ្រងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី" និងមានភ្ជាប់មកជាមួយនូវលិខិតឆ្លើយឆ្លងជាមួយធនាគារអភិវឌ្ឍន៍អាស៊ីកន្លងមក និងកំណត់ហេតុប្រជុំពាក់ព័ន្ធកាលពីមុនស្ដីពីបណ្ដឹងតវ៉ាអំពីការដោះស្រាយផលប៉ះពាល់ (iv) បញ្ជីឈ្មោះអ្នកភូមិ ១៧០នាក់បន្ថែមទៀត[៥] "ដែលអ្នកទាំងនោះជាជនរងផលប៉ះពាល់ដោយគម្រោង ប៉ុន្តែមិនទាន់ទទួលបានសំណងសមរម្យ និងយុត្តិធម៌ ហើយកំពុងតែទទួលទុក្ខលំបាក" ព្រមទាំងសុំឱ្យការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស ធ្វើការអង្កេតលើករណីបណ្ដឹងតវ៉ា និង (v) សេចក្ដីយោងទៅទាក់ទងនឹងសវនកម្មលើការដោះស្រាយផលប៉ះពាល់ និងរបាយការណ៍សម្រាប់ប្រទេសកម្ពុជា ដែលរៀបចំឡើងក្រោមជំនួយបច្ចេកទេសលេខ ៦០៩១-REG ។ ដើមបណ្ដឹងក៏បាននិយាយទៀតថា ពួកគាត់មិនសុំឱ្យលាក់អត្តសញ្ញាណរបស់ខ្លួនទេ ហើយថាពួកគាត់ផ្ដល់សិទ្ធិឱ្យការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស ក្នុងការផ្សព្វផ្សាយព័ត៌មានអំពីបណ្ដឹងនេះ។

## គ. ការកំណត់លក្ខណៈសម្បត្តិ

៧. បេសកកម្មកំណត់លក្ខណៈសម្បត្តិនៃបណ្ដឹង មានគម្រោងធ្វើទស្សនកិច្ចនៅកម្ពុជាភ្លាមបន្ទាប់ពីទទួលបានព័ត៌មានបន្ថែមទាំងនោះ នៅចន្លោះពេលពីថ្ងៃទី២១ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៧។ បេសកកម្មនេះ គឺមានបំណងប្រមូលព័ត៌មានសម្រាប់ការត្រួតពិនិត្យ និងការវាយតម្លៃលើពាក្យបណ្ដឹងនោះ បន្ថែមលើការកំណត់លក្ខណៈសម្បត្តិនៃបណ្ដឹង។ ប៉ុន្តែ កាលពីថ្ងៃទី១៧ ខែសីហា ២០០៧ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានស្នើឱ្យផ្អាកបេសកកម្មនេះសិន ព្រោះក្រសួងកំពុងតែពិភាក្សាជាមួយ អង្គការវេទិកាអង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជា ទាក់ទងនឹងបណ្ដឹងលើគម្រោងនេះ ដោយសារក្រសួងយល់(ច្រឡំ)ថា អ្នកប្ដឹងជាក្រុមមនុស្សតែមួយ ដែលបានដែលប្ដឹងមកការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស ។ ក្រោយពីទទួលបានការស្រាយបំភ្លឺលើភាពមិនគងជាន់គ្នានៃបណ្ដឹង និងដោយមានការជួយតវ៉ាពីសំណាក់ និវាសនដ្ឋានបេសសកម្មប្រចាំកម្ពុជា (CARM) និង ការធានាថាបេសកកម្មអង្កេតនេះនឹងផ្ដោតតែលើការកំណត់លក្ខណៈសម្បត្តិនៃបណ្ដឹងនេះ នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ ២០០៧ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានទទួលយកសំណើរបស់ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស ហើយអនុញ្ញាតឱ្យបេសកកម្មធ្វើសកម្មភាពចាប់ពីថ្ងៃទី២៩ ខែសីហា ដល់ថ្ងៃទី៣ ខែកញ្ញា ២០០៧។ ដូច្នេះ បេសកកម្មដែលរួមមានអ្នកសម្របសម្រួលគម្រោងពិសេស បានមកដល់កម្ពុជាកាលពីថ្ងៃទី២៨ ខែសីហា ហើយបានបញ្ចប់បេសសកម្ម នៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ ២០០៧។

៨. បេសកកម្មបានជួបពិគ្រោះជាមួយបុគ្គលិកពាក់ព័ន្ធរបស់ និវាសនដ្ឋានបេសសកម្មប្រចាំកម្ពុជា（CARM）បុគ្គលិករបស់អង្គការអភិរក្ស និងអភិវឌ្ឍន៏កម្ពុជា（CDCam）មន្ត្រីរបស់គណៈកម្មការអន្តរក្រសួងសម្រាប់ដោះស្រាយផលប៉ះពាល់គម្រោង（IRC）អគ្គលេខាធិការរងរបស់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអ្នកដឹកនាំសហគមន៍ពីរនាក់ទៀតដែលជាអ្នកដាក់ពាក្យបណ្តឹង។ ក្រុមបេសកកម្មបានធ្វើដំណើរទៅកាន់ សហគមន៍ក្រាំងក្អុក ដើម្បីធ្វើការពិភាក្សាជាមួយប្រធានសហគមន៍ទាំងពីរ និងបានពិភាក្សានៅក្នុងផ្ទះរបស់ អ្នកស្រី ស៊ិន ឈិន រួចបង្ហួសទៅមើលទីកន្លែងផ្លាស់ប្តូរទីតាំងថ្មីនៅ ស្ទឹងស្លូត។ បញ្ហារបស់ដើមបណ្តឹងត្រូវបានលើកឡើងច្រើនឆ្នាំមកហើយ ប៉ុន្តែបច្ចុប្បន្ននៅមិនទាន់បានដោះស្រាយនៅឡើយ។ ជនរងផលប៉ះពាល់ដែលជាដើមបណ្តឹងបានបង្ហាញយ៉ាងច្បាស់លាស់ថាពួកគាត់មានអារម្មណ៏ថាការរស់នៅរបស់គាត់កាន់តែពិបាកឡើង១ ពោលគឺ ក្រោយពីពេលមានគម្រោងនេះ ហើយថាពួកគាត់គួរសាកសមទទួលបាននូវជំនួយបន្ថែមទៀត ក្រៅពីសំណងដែលសងតាមលទ្ធផលនៃសវនកម្មលើការដោះស្រាយផលប៉ះពាល់។ ផ្អែកលើការរកឃើញរបស់ក្រុមបេសកកម្ម បណ្តឹងតវ៉ានេះត្រូវបានកំណត់ និងប្រកាសនៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ ថាជាបណ្តឹងដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

## ២. ការត្រួតពិនិត្យ និងវាយតម្លៃ

### ក. គោលបំណង និងវិធីសាស្ត្រ

៩. គោលបំណងរបស់ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស (OSPF) គឺដើម្បីជួយដល់អ្នកពាក់ព័ន្ធទាំងឡាយក្នុងការស្វែងរកដំណោះស្រាយលើបញ្ហានានាដែលលើកឡើងដោយដើមបណ្តឹង និង ដើម្បីផ្តួចផ្តើម ព្រមទាំងដឹកនាំដំណើរការពិគ្រោះយោបល់។ ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស ផ្តល់ជំនួយដល់ភាគីពាក់ព័ន្ធក្នុងការដោះស្រាយបញ្ហា តាមរយៈ (i) ការផ្តល់ឱ្យអ្នកដាក់ពាក្យបណ្តឹងនូវបរិយាកាសអំណោយផលសម្រាប់ជាជំនួយដល់ការសម្រេចចិត្តរបស់ពួកគាត់ ផ្តល់ឱកាសឱ្យពួកគាត់បានជួបនិងពិភាក្សាពីយុទ្ធសាស្ត្រនានាក្នុងដោះស្រាយបញ្ហា ប្រមូលព័ត៌មានចំបាច់ផ្សេងដែលត្រូវការ និង (ii) រៀបចំស្ថានភាពសម្រាប់ភាគីពាក់ព័ន្ធទាំងអស់ឱ្យចូលរួមរកដោះស្រាយបញ្ហា។ ការងារទទួលខុសត្រូវរបស់ ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស គឺត្រូវធ្វើការជាមួយភាគីទាំងអស់ដោយមានការគោរពយកចិត្តទុកដាក់ចំពោះភាគី និងធានាឱ្យមាននីតិវិធីប្រកបដោយយុត្តិធម៌។ ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស គ្មានតួនាទីក្នុងការសម្រេចថាខុសឬត្រូវទេ គ្មានតួនាទីលើការដោះស្រាយបញ្ហា និង មិនស្វែងរកការពិត ឬធ្វើជាអាជ្ញាកណ្តាល ដែលលំអៀងទៅភាគីណាមួយនោះទេ។ របាយការណ៍ត្រួតពិនិត្យ និងវាយតម្លៃនេះ (RAR) គឺគ្មានគោលបំណងផ្តល់នូវការវិនិច្ឆ័យជាក់លាក់លើបញ្ហាណាមួយទាក់ទងនឹងគម្រោង គ្មានបំណងធ្វើការវាយតម្លៃលើក្រុមអ្នកពាក់ព័ន្ធណាមួយឬបុគ្គលណាមួយ ឬ គ្មានចេតនាផ្តល់ជាកម្រងអនុសាសន៍របស់អ្នកជំនាញដែលបង្ហាញពីរបៀបដោះស្រាយបញ្ហាទេ។ របាយការណ៍នេះ គឺគ្រាន់តែមានគោលបំណងជំនួយដល់អ្នកពាក់ព័ន្ធទាំងឡាយឱ្យយល់ពីវត្ថុបំណង និងកង្វល់ទាំងឡាយ របស់គ្នាទៅវិញទៅមក និង សម្រាប់ជំរុញឱ្យអ្នកទាំងនោះរកជម្រើសនានាសម្រាប់ដោះស្រាយបញ្ហាទាំងនោះ។ តាមអត្ថន័យនេះ របាយការណ៍ត្រួតពិនិត្យ និងវាយតម្លៃនេះ បង្ហាញនូវការវាយតម្លៃឯករាជ្យ និងអព្យាក្រឹត្យ ហើយនឹងត្រូវចែកជូនដល់អ្នកប្តឹងទាំអស់ (ដែលមានទាំងភាសាខ្មែរ និងអង់គ្លេស) និង ជូនដល់ និវាសនដ្ឋានបេសសកម្មប្រចាំកម្ពុជា (CARM) មុនគេ។ នៅពេលដែលដើមបណ្តឹងសម្រេចបន្តដំណើរការពិគ្រោះយោបល់តទៅទៀត ហើយបើទាំងដើមបណ្តឹង និង និវាសនដ្ឋានបេសសកម្មប្រចាំកម្ពុជា ឯកភាពយល់ព្រម របាយការណ៍នេះនឹងត្រូវដាក់ជូនរដ្ឋាភិបាលផងដែរ។

១០. ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស មានផែនការបំពេញបេសសកម្មនៅកន្លែងកើតបញ្ហាដោយផ្ទាល់ដើម្បីធ្វើការត្រួតពិនិត្យ និងវាយតម្លៃ តាមរយៈ ការជួបពិភាក្សាជាមួយអ្នកពាក់ព័ន្ធទាំងអស់ អំពីបណ្តឹង និងវិធីសាស្ត្រដែលអាចឈានទៅរកដំណោះស្រាយបញ្ហា ប៉ុន្តែ រដ្ឋាភិបាលបានស្នើសុំថា បេសកកម្មនេះគួរពន្យារពេលចុះមក

ពិនិត្យរហូតដល់រដ្ឋាភិបាល បានប្រមូលផ្តុំសព្វគ្រប់នូវរាល់បញ្ហាទាក់ទងនឹងការដោះស្រាយផលប៉ះពាល់នោះសិន។ ដូច្នេះ ការត្រួតពិនិត្យ និងវាយតម្លៃនេះ (ជាជំហានទី៤ នៃដំណើរការពិគ្រោះយោបល់) គឺធ្វើឡើង តាមរយៈ (i) ឯកសារដែលផ្តល់ឱ្យដោយដើមបណ្តឹង (ii) ឯកសារចងក្រងរក្សាទុកដោយធនាគារអភិវឌ្ឍន៍អាស៊ី និង (iii) ការរកឃើញរបស់បេសសកម្មកំណត់លក្ខណៈសម្បត្តិនៃបណ្តឹង ក្រោមសកម្មភាពរបស់ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស(OSPF)។ យោងតាមលក្ខខណ្ឌនៃគោលនយោបាយទំនាក់ទំនងសាធារណៈ[៤]របស់ធនាគារអភិវឌ្ឍន៍អាស៊ី របាយការណ៍នេះនឹងចេញផ្សព្វផ្សាយជាសារធារណៈនៅក្នុងដំណាក់កាលក្រោយទៀត ប្រសិនបើមានការឯកភាពយល់ព្រមពីដើមបណ្តឹង និងរដ្ឋាភិបាល ជាមុនសិន។

## ខ. ការកំណត់អ្នកពាក់ព័ន្ធ

### ១. ដើមបណ្តឹង

១១. ដើមបណ្តឹងមានពីរក្រុមសំខាន់ៗ។ ក្រុមទី១ មានអ្នកប្តឹង៦៣នាក់ ដែលមានឈ្មោះក្នុងលិខិតពីរ ហើយដែលការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស បានទទួលលិខិតទាំងពីរនេះកាលពីថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧ ក្នុងនោះលិខិតមួយមកពីសហគមន៍ក្រាំងក្អុក (មានអ្នកប្តឹង៤១នាក់) និងលិខិតមួយទៀតមកពីសហគមន៍ស្ទឹងស្លូត (មានអ្នកប្តឹង២២នាក់) នៅខេត្តព្រៃវែង។ លិខិតដើមបានលើកឡើងពីបញ្ហាជាច្រើនទាក់ទងនឹងដើមបណ្តឹងរបស់អ្នកប្តឹងទាំង៦៣នាក់ ដែលក្នុងនោះរួមមាន បញ្ហាក្រីក្រ ការលំបាកក្នុងជីវភាពរស់នៅ ការជំពាក់បំណុល និង បញ្ហាប័ណ្ណកម្មសិទ្ធិដីធ្លី។

១២. ក្រុមទីពីរមានឈ្មោះមនុស្ស១៧៧នាក់ ដែលមានរាយនាមក្នុងតារាងមួយ ដែលការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស បានទទួលកាលពីថ្ងៃទី ២០ ខែសីហា ឆ្នាំ២០០៧។ ក្នុងចំណោមអ្នកទាំងនោះ ពួកគាត់មកពីសហគមន៍ផ្សេងៗគ្នាក្នុងខេត្តទាំងពីរ (គឺខេត្តព្រៃវែង និងខេត្តស្វាយរៀង)។ មានមនុស្ស ៧នាក់ ក្នុងចំណោម៦៣នាក់ ដែលឋិតនៅក្នុងក្រុមទី១ ក៏មានឈ្មោះក្នុងក្រុមទី២នេះដែរ។ បញ្ជីឈ្មោះមនុស្ស ទាំង១១៧ នាក់ គឺមានអមជាមួយលិខិតមួយទៀត ដែលមានចុះហត្ថលេខាដោយប្រធានសហគមន៍ទាំងពីរនាក់ ដែលធ្លាប់ចុះហត្ថលេខាលើលិខិតពីរដំបូងដែលមានដើមបណ្តឹង៦៣នាក់ និងមានបន្ថែមសេចក្តីអះអាងថា "ក្រៅពីសមាជិកសហគមន៍របស់យើងខ្ញុំ ក៏នៅមានអ្នកភូមិដ៏ច្រើនផ្សេងទៀត ដែលរងផលប៉ះពាល់ដោយសារគម្រោង ហើយដែលអ្នកភូមិទាំងនោះនៅមិនទាន់

៤. គោលនយោបាយទំនាក់ទំនងសាធារណៈរបស់ ADB ឆ្នាំ២០០៥។ សូមមើលវាក្យខណ្ឌ ១១៩ (iv) ។

បានសំណងដែលសមរម្យ និង យុត្តិធម៌ នៅឡើយ ព្រមទាំងកំពុងតែជួបប្រទះការលំបាក"។ សូមអានតារាង ឧបសម្ព័ន្ធ ទី៨ (បញ្ជីឈ្មោះមនុស្សទាំង១១៧នាក់) ដើម្បីដឹងពីបញ្ហាចម្បង១របស់បុគ្គលនីមួយ។ យើងសូមឱ្យ អ្នកសម្រប សម្រួលគម្រោងពិសេស ធ្វើការអង្កេតករណីទាំងនោះផងដែរ"។ បើយោងតាមបញ្ជីឈ្មោះនោះ យើងអាចបែង ចែកមនុស្សទាំង ១១៧នាក់ចេញជាពីក្រុម ពោលគឺ "ក្រុមដែលមិនធ្លាប់ទទួលបានសំណងទាល់តែសោះ" និងក្រុម ដែល"មិនទាន់ទទួលសំណងគ្រប់គ្រាន់"។ គ្មានបង្ហាញពីបញ្ហាដែលបានលើកឡើងក្នុងករណីបណ្ដឹងរបស់មនុស្ស ៦៣នាក់ ដូចជា ភាពក្រីក្រ ការលំបាកក្នុងជីវភាពរស់នៅ ការជំពាក់បំណុល និងបញ្ហាប័ណ្ណកម្មសិទ្ធិដីធ្លី ទេ។ ក្នុងអំឡុង ពេលបេសកកម្មកំណត់លក្ខណៈសម្បត្តិនៃបណ្ដឹង ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស រកឃើញថាមនុស្ស ទាំង ១១៧នាក់នោះ ឋិតក្នុងចំណោមមនុស្ស ដែលអង្គការវេទិការបស់អង្គការមិនមែនរដ្ឋាភិបាល បានលើកឡើងដែរ ហើយការលើកឡើងនេះ កំពុងត្រូវបានពិនិត្យពិចារណាដោយ គណៈកម្មការអន្តរក្រសួងសម្រាប់ដោះស្រាយផលប៉ះ ពាល់គម្រោង (IRC) និង ក៏កំពុងត្រូវបាន និវាសនដ្ឋានបេសសកម្មប្រចាំកម្ពុជា(CARM) យកមកពិចារណាផងដែរ។

១៣. មនុស្សទាំង១១៧នាក់ មិនបានចុះហត្ថលេខា ឬ ផ្ដិតមេដៃលើលិខិតឯកសារផ្ញើមកកាន់ ការិយាល័យ អ្នកសម្របសម្រួលគម្រោងពិសេស ទេ ហើយពួកគាត់ក៏ មិនបានផ្ដល់ធ្វើលិខិតប្រគល់សិទ្ធិឱ្យប្រធានសហគមន៍ទាំងពីរ ធ្វើជាអ្នកតំណាងរបស់ពួកគាតលដែរទេ។ លើសពីនេះទៀត លិខិតឯកសារទំនាក់ទំនងដែលបានរៀបរាប់ក្នុងកថាខណ្ឌ ទី១៧ ខាងក្រោម គឺមានអមជាមួយស្នាមមេដៃរបស់អ្នកប្ដឹងពីដើមតែ៦៣នាក់ប៉ុណ្ណោះ ហើយមិនមានរៀបរាប់អំពី មនុស្ស ១១៧នាក់នេះទេ។

១៤. ជាការសង្ខេបឡើងវិញ ករណីរបស់ក្រុមមនុស្សទីពីរ គឺកំពុងស្ថិតនៅក្នុងការពិចារណាយ៉ាងយកចិត្តទុកដាក់ របស់គណៈកម្មការអន្តរក្រសួងសម្រាប់ដោះស្រាយផលប៉ះពាល់ (IRC) និង និវាសនដ្ឋានបេសសកម្មប្រចាំកម្ពុជា (CARM)។ បញ្ហាក្នុងករណីរបស់ក្រុមទី២នេះ គឺហាក់ដូចជាកម្រិតត្រឹមតែចំនួនអត្រាសំណងដែលបានព្រមព្រៀង នៅក្នុងពេលធ្វើសវនកម្មលើការដោះស្រាយផលប៉ះពាល់ ពោលគឺមិនបញ្ចូលបញ្ហាដែលលើកឡើងក្នុងករណីរបស់ អ្នកប្ដឹង៦៣នាក់នោះទេ ហើយអ្នកទាំង ១១៧ មិនបានចុះហត្ថលេខា ឬ ផ្ដិតមេដៃនៅលើពាក្យបណ្ដឹង ឬ មិនបានធ្វើ ការប្រគល់សិទ្ធិជាផ្លូវការឱ្យប្រធានសហគមន៍ធ្វើជាតំណាងរបស់ខ្លួនទេ។ ដូច្នេះ ការិយាល័យអ្នកសម្របសម្រួល គម្រោងពិសេស ធ្វើការសន្និដ្ឋានថា អ្នកទាំង១១៧នេះមិនគួរទទួលស្គាល់ថាជាដើមបណ្ដឹង នៅករណីចំពោះមុខនេះទេ លើកលែងតែ មនុស្ស៧នាក់ដែលមានឈ្មោះក្នុងបញ្ជីដើមបណ្ដឹងទាំង៦៣នាក់ពីខាងដើម ដែលគួរទទួលស្គាល់ជា ដើមបណ្ដឹង។

## ២. អង្គការមិនមែនរដ្ឋាភិបាល

១៥. ពាក្យបណ្តឹងត្រូវបានដាក់ជូន ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស ដោយអង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជាមួយ មានឈ្មោះហៅថា អង្គការអភិរក្ស និង អភិវឌ្ឍន៍កម្ពុជា (CDCam) និងមានសេចក្តីអះអាងរបស់អ្នកដឹកនាំភូមិពីររូបថា "យើងសូមប្រគល់សិទ្ធិជូនលោក សូត្រ សុផុន ប្រធានស្តីទីនៃ... CDCam ឱ្យធ្វើជាអ្នកទំនាក់ទំនងរបស់យើង"។ ដូច្នេះ ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស ចាត់ទុកអង្គការអភិរក្ស និងអភិវឌ្ឍន៍កម្ពុជា (CDCam) ជាច្រកទំនាក់ទំនងរវាងដើមបណ្តឹង ជាមួយនឹង ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស ហើយមិនមិនចាត់ទុកថា CDCam ជាអ្នកតំណាងឱ្យដើមបណ្តឹងទេ។ ក្នុងអំឡុងបេសកកម្មកំណត់លក្ខណៈសម្បត្តិនៃបណ្តឹង អង្គការអភិរក្ស និងអភិវឌ្ឍន៍កម្ពុជា និងប្រធានភូមិពីររូបក៏បានបញ្ជាក់ពីតួនាទីត្រឹមតែជាច្រកទំនាក់ទំនងនេះដែរ។

១៦. តែយ៉ាងណាក៏ដោយ កាលពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០០៧ ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេសបានទទួលលិខិតពីរមកពីសហគមន៍ទាំងពីរ ក្នុងនោះមានស្នាមមេដៃរបស់ដើមបណ្តឹង៦៣នាក់ អះអាងថា "យើងមានបំណងផ្ទេរសិទ្ធិសម្រាប់ការសម្របសម្រួល ការរៀបចំបណ្តឹង និង ការលើកសំណើផ្សេងៗរបស់សហគមន៍យើងសម្រាប់ដោះស្រាយបញ្ហាឱ្យទៅ លោក សូត្រ សុផុន ដែល ជាប្រធានស្តីទីរបស់ [CDCam]...។ យើងសូមប្រាប់ទៅអ្នកថា ដោយសារយើងមិនមានចំណេះដឹងគ្រប់គ្រាន់ មិនដឹងពីនីតិវិធី មិនដឹងពីរបៀបរៀបចំបណ្តឹង និងមិនចេះអានទាំងភាសាខ្មែរ ឬ ភាសាអង់គ្លេសឡើយ។ សូមមេត្តាទទួលនូវសំណើរបស់យើងខ្ញុំដូចដែលបានស្នើឡើងនេះ"។ ដូច្នេះតាមលិខិតពីរដែលផ្ញើរមកក្រោយនេះ ដើមបណ្តឹង បានផ្តល់សិទ្ធិឱ្យអង្គការអភិរក្ស និងអភិវឌ្ឍន៍កម្ពុជា (CDCam) ធ្វើជាអ្នកតំណាងឱ្យពួកគាត់។

១៧. មានអង្គការមិនមែនរដ្ឋាភិបាលផ្សេងៗ ក្រៅពី អង្គការអភិរក្ស និងអភិវឌ្ឍន៍កម្ពុជា (CDCam) បានចូលប្រឡូកក្នុងការតស៊ូមតិសម្រាប់ជាប្រយោជន៍ ដល់ជនរងផលប៉ះពាល់ដោយសារគម្រោងនេះ ចាប់តាំងពីឆ្នាំ២០០២ផងដែរ។ អង្គការទាំងនោះ រួមមានទាំង អង្គការវេទិកាអង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជា និងអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា ដែលបានបញ្ជូនលិខិតមួយមកជូនធនាគារអភិវឌ្ឍន៍អាស៊ី (ADB) កាលពីឆ្នាំ២០០២ ដោយបានលើកឡើងអំពីបញ្ហាធំៗទាក់ទងនឹងការដោះស្រាយផលប៉ះពាល់។ លើសពីនោះមាន អង្គការឃ្លាំមើលមេគង្គ (Mekong Watch) ដែលបានចូលរួមក្នុងកិច្ចប្រជុំជាច្រើនទាក់ទងនឹងការដោះស្រាយផលប៉ះពាល់របស់គម្រោង ព្រមទាំងភ្នាក់ងារគម្រោងគណនេយ្យភាពអន្តរជាតិ (International Accountability Project) ដែលបានជួយរៀបចំបទបង្ហាញស្តីពី

ការដោះស្រាយផលប៉ះពាល់គម្រោង នៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំ២០០៧របស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និង មជ្ឈមណ្ឌលព័ត៌មានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដែលបានណែនាំដល់ដើមបណ្តឹងអំពីរបៀបដាក់ពាក្យបណ្តឹង។ ការរៀបរាប់នេះអាចមិនទាន់រាប់អស់ឈ្មោះអង្គការដែលបានផ្តោតការយកចិត្តទុកដាក់លើបញ្ហាដោះស្រាយផលប៉ះពាល់របស់គម្រោងនេះទេ។ យ៉ាងណាក៏ដោយ អង្គការទាំងនេះសុទ្ធតែមានផលប្រយោជន៍ក្នុងដំណោះស្រាយរាល់បញ្ហា ដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹង។

### ៣. ស្ថាប័នរដ្ឋាភិបាល

១៨. ស្ថាប័នរដ្ឋចម្បងដែលមានការពាក់ព័ន្ធនឹងពាក្យបណ្តឹង និង បញ្ហាដោះស្រាយផលប៉ះពាល់នៅកម្ពុជា គឺគណៈកម្មការអន្តរក្រសួងសម្រាប់ដោះស្រាយផលប៉ះពាល់(IRC) ដែលស្ថិតក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ គណៈកម្មការអន្តរក្រសួងសម្រាប់ដោះស្រាយផលប៉ះពាល់ មានភារកិច្ចទទួលខុសត្រូវលើ រាល់បញ្ហាទាក់ទងនឹងការដោះស្រាយផលប៉ះពាល់គម្រោងក្នុងប្រទេសកម្ពុជា ហើយ ច្បាស់ណាស់ជាអ្នកដែលមានផលប្រយោជន៍នៅក្នុងបណ្តឹងដែលបានធ្វើឡើងទាក់ទងនឹងការដោះស្រាយផលប៉ះពាល់នេះ។ គណៈកម្មការអន្តរក្រសួងសម្រាប់ដោះស្រាយផលប៉ះពាល់ បានចូលរួមពាក់ព័ន្ធយ៉ាងសកម្មនៅក្នុងការអនុវត្តតាមអនុសាសន៍របស់សវនកម្មលើការដោះស្រាយផលប៉ះពាល់គម្រោង ហើយបានខិតខំប្រឹងប្រែងធ្វើការទាំងនេះយ៉ាងខ្លាំង។ គណៈកម្មការអន្តរក្រសួងសម្រាប់ដោះស្រាយផលប៉ះពាល់ ក៏បានចូលរួមក្នុងការពិភាក្សានាពេលថ្មីៗនេះ ទាក់ទងនឹងករណីនៅសល់ដែលកំណត់រកឃើញដោយសវនកម្ម។ លទ្ធផលមួយផ្នែកដែលបានមកពីកិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់នោះ គណៈកម្មការអន្តរក្រសួងសម្រាប់ដោះស្រាយផលប៉ះពាល់(IRC) មិនមានជំហរគាំទ្រចំពោះពាក្យបណ្តឹងថ្មីៗនេះទេ ដោយសារគណៈកម្មការអន្តរក្រសួងនេះ យល់ថាករណីនេះ មានភាពស្មុគ្រស្មាញជាប់ពាក់ព័ន្ធគងជាន់គ្នានឹងករណីដែលកំពុងតែធ្វើការពិភាក្សាគ្នា ហើយ មិនលក្ខណៈសម្រួលដល់ការដោះស្រាយករណីទាំងនោះប្រកបដោយជោគជ័យទេ។ ក្រៅពី គណៈកម្មការអន្តរក្រសួងសម្រាប់ដោះស្រាយផលប៉ះពាល់ ក៏មាន ស្ថាប័នរបស់រដ្ឋនៅថ្នាក់ខេត្ត និងថ្នាក់ស្រុក មួយចំនួន មានផលប្រយោជន៍ពាក់ព័ន្ធការដោះស្រាយបញ្ហាបណ្តឹង ផងដែរ ដោយសារស្ថាប័នរដ្ឋ ទាំងនោះមានតួនាទីក្នុងការផ្តល់កម្មសិទ្ធដីធ្លី ឬ ចេញលិខិតបញ្ជាក់កាន់កាប់ដី។

### ៤. និវាសនដ្ឋានបេសកកម្មប្រចាំប្រទេសកម្ពុជា នៃធនាគារអភិវឌ្ឍន៍អាស៊ី

១៩. ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និង និវាសនដ្ឋានបេសកកម្មប្រចាំប្រទេសកម្ពុជា (CARM) មានតួនាទីផលប្រយោជន៍សំខាន់ណាស់ក្នុងគម្រោងនេះ។ ធនាគារអភិវឌ្ឍន៍អាស៊ី បានផ្តល់កម្ចី៤០លានដុល្លា សម្រាប់អនុវត្តគម្រោងនេះ និងផ្តល់ជំនួយបច្ចេកទេស ចំនួន ៥០០.០០០ដុល្លា សម្រាប់ការងារមួយចំនួន ដែលក្នុងចំណោមការងារទាំងនោះ រួមមាន ការងារសវនកម្មលើការដោះស្រាយផលប៉ះពាល់គម្រោងនេះ។ ធនាគារអភិវឌ្ឍន៍អាស៊ី បានកំពុងធ្វើការយកចិត្តទុកដាក់យ៉ាងខ្លាំងលើគម្រោង និងលើបញ្ហាដោះស្រាយផលប៉ះពាល់គម្រោង ជាពិសេស លើការអនុវត្តតាមអនុសាសន៍របស់សវនកម្មលើការដោះស្រាយផលប៉ះពាល់។ បញ្ហាចម្បងចុងក្រោយ ដែលមានបញ្ជាក់នៅក្នុងរបាយការណ៍សវនកម្ម គឺកំពុងត្រូវបានពិចារណាដោយ និវាសនដ្ឋានបេសកកម្មប្រចាំប្រទេសកម្ពុជា (CARM) ដោយមានការចូលរួមពី គណៈកម្មការអន្តរក្រសួងសម្រាប់ដោះស្រាយផលប៉ះពាល់។ និវាសនដ្ឋានបេសកកម្មប្រចាំប្រទេសកម្ពុជា (CARM) ដែលបានធ្វើរដ្ឋបាលកិច្ចលើគម្រោងនេះ តាំងពីថ្ងៃទី០៥ ខែមេសា ឆ្នាំ២០០២ ក៏ជាអ្នកមានផលប្រយោជន៍ពាក់ព័ន្ធសំខាន់មួយផងដែរ ហើយនឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការរកដំណោះស្រាយចំពោះបណ្តឹងនេះ។

## គ. ការកំណត់អត្តសញ្ញាណបញ្ហានៃបណ្តឹង

២០. ក្នុងពាក្យបណ្តឹង អ្នកប្តឹងបានលើកឡើងនូវបញ្ហាជាច្រើន ដូចដែលមានរៀបរាប់ក្នុងកថាខណ្ឌទី៤ ខាងលើរួចហើយ។ បញ្ហាទាំងឡាយនោះ អាច បែងចែកជាពីក្រុមធំៗ : (i) ប័ណ្ណកម្មសិទ្ធិដីធ្លី និង (ii) ភាពក្រីក្រចុះដុនដាប។

### ១. ប័ណ្ណកម្មសិទ្ធិដីធ្លី

២១. ដើមបណ្តឹងបានបង្ហាញនូវកង្វល់យ៉ាងខ្លាំងថា ពួកគាត់មិនទាន់បានទទួលប័ណ្ណកម្មសិទ្ធិដីធ្លីនៅកន្លែងដែលគាត់បានទៅរស់នៅប្រើប្រាស់ បន្ទាប់ពីគាត់ចាកចេញពីទីតាំងចាស់ដែលត្រូវប៉ះពាល់ដោយគម្រោងសង់ផ្លូវជាតិនោះនៅឡើយ។ ដោយសារមានសកម្មភាពចរាចរ និងសកម្មភាពពាណិជ្ជកម្មកាន់សកម្មច្រើនឡើងនៅតាមដងផ្លូវដែលត្រូវបានស្តារឱ្យប្រសើរជាងមុននេះ បានធ្វើឱ្យដីនៅជាប់ផ្លូវនោះកាន់តែមានមនុស្សចង់បានច្រើន ហើយដើមបណ្តឹងមានកង្វល់ថា ប្រសិនបើគ្មានប័ណ្ណកម្មសិទ្ធិដីធ្លីទេនោះ ពួកគាត់អាចនឹងប្រឈមមុខនូវភាពងាយរងគ្រោះដោយសារអ្នកមានអំណាចអាចនឹងធ្វើលទ្ធកម្មយកដីធ្លីរបស់ពួកគាត់។

២២. ប័ណ្ណកម្មសិទ្ធិដីធ្លី ត្រូវបានសន្យានៅក្នុងផែនការស្តីពីការដោះស្រាយផលប៉ះពាល់ថានឹងផ្តល់ឱ្យជនរងផលប៉ះពាល់ (សូមមើលឧបសម្ព័ន្ធ១៣ កថាខណ្ឌ២២)។ គណៈកម្មការអន្តរក្រសួងសម្រាប់ដោះស្រាយផលប៉ះពាល់ (IRC)

ប្រកាន់ជំហរថា តាមច្បាប់របស់កម្ពុជា[៥] ប័ណ្ណកម្មសិទ្ធិដីអាចនឹងផ្តល់ឱ្យជនរងផលប៉ះពាល់តែក្នុងករណីក្រោយពីពួកគាត់បានរស់នៅទីនោះអស់រយៈពេល៥ឆ្នាំ សិន។ សម្រាប់តំបន់ផ្លាស់ប្តូរទីតាំង នៅក្នុងសហគមន៍ ស្ទឹងស្លួត ជនរងផលប៉ះពាល់ (APs) បានទៅតាំងទីរស់នៅប្រើប្រាស់ដីនោះនៅចុងឆ្នាំ២០០៣ ដូច្នេះ មានន័យថា ពួកគាត់គួរនឹងបានបំពេញលក្ខខណ្ឌរស់នៅប្រើប្រាស់រយៈពេល៥ឆ្នាំ នៅឆ្នាំ២០០៨ខាងមុខនេះ។ ចំពោះជនរងផលប៉ះពាល់ ដែលបានផ្លាស់ប្តូរទៅកន្លែងទីតាំងផ្សេងទៀត ក្រោយពីទីជំរកផ្ទះសម្បែងរបស់គាត់ត្រូវបានរុះរើ គឺពួកគាត់បានទៅរស់នៅទីតាំងថ្មីនោះច្រើនជាង៥ឆ្នាំហើយ។ ដើមបណ្តឹងជឿថា ការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី ត្រូវធ្វើឱ្យបានឆាប់រហ័សដើម្បីការពារពួកគាត់ពីការបាត់បងដី។

## ២. ភាពក្រីក្រចុះដុនដាប

**២៣.** ដើមបណ្តឹងជាច្រើនបានបាត់បង់ប្រភពសម្រាប់ទ្រទ្រង់ជីវភាពរស់នៅរបស់ខ្លួន ដោយសារត្រូវបង្ខំចិត្តប្តូរទីកន្លែងរស់នៅប្រកបរបររកស៊ី ហើយគ្មានកម្មវិធីណាមួយដែលផ្តល់ឱ្យគាត់សម្រាប់ស្តារជីវភាពរស់នៅរបស់គាត់ឡើងវិញទេក្រោយពីផ្លាស់ប្តូរទីតាំង។ បន្ទាប់ពីការផ្លាស់ប្តូរទីតាំង និងក្នុងអំឡុងពេល៥ ឬ ៦ឆ្នាំ ពោលគឺក្រោយពីការផ្លាស់ប្តូរទីតាំងនៅឆ្នាំ២០០០ មកទល់ពេលទទួលបានសំណងនៅឆ្នាំ២០០៥-២០០៦ (ក្រោយពីមានការធ្វើសវនកម្មលើការដោះស្រាយផលប៉ះពាល់គម្រោងនេះ) ដើមបណ្តឹងមួយចំនួនធំ មានការខ្វះខាតប្រាក់សម្រាប់ទិញដី និង ធ្វើផ្ទះថ្មីជំនួសវិញ ព្រមទាំងតម្រូវការប្រចាំថ្ងៃផ្សេងៗទៀត។ ដោយសារការបាត់បង់ប្រភពរកប្រាក់ចំណូលពីមុនមក ក្នុងកំរិតតិច ឬ ច្រើនទៅតាមករណីបុគ្គលម្នាក់ៗ និង មិនអាចមានលទ្ធភាពខ្ចីប្រាក់ពីធនាគារពាណិជ្ជកម្មបាន ព្រោះគ្មានប័ណ្ណកម្មសិទ្ធិលើដីធ្លី ដើមបណ្តឹងជាច្រើនត្រូវបានរាយការណ៍ថា ពួកគាត់បានទៅខ្ចីប្រាក់ពីអ្នកចងការប្រាក់ ដែលយកអត្រាការប្រាក់ខ្ពស់ (ពី១០ ទៅ២០ ឬ អាចដល់ទៅ៣០% ក្នុងមួយខែ)។ ដូច្នេះ ពួកគាត់បានធ្លាក់ចូលក្នុងអន្ទាក់បំណុល ពោលគឺជំពាក់គេ ពី ២០០ ឬ ៣០០ រហូតដល់ជាង១០០០ដុល្លា ក្នុងម្នាក់ ហើយពួកគាត់មិនសង្ឃឹមថាអាចមានលទ្ធភាពសងបំណុលនោះរួចវិញដោយខ្លួនឯងទេ[៦]។ ដើមបណ្តឹងជឿថា កម្មវិធីទ្រទ្រង់ជីវភាពរស់នៅ និងប្រាក់ឧបត្ថម្ភដើម្បីរំលួសបំណុល គឺមានសារៈសំខាន់ណាស់សម្រាប់ស្តារលក្ខខណ្ឌរស់នៅរបស់គាត់ឱ្យបានស្មើនឹងស្ថានភាពដែលពួកគាត់មានមុនពេលមានគម្រោង។

---

៥ អនុក្រឹត្យ លេខ ១៩ អនក្រ.បក ស្តីពីសម្បទានដីសង្គមកិច្ច មាត្រា ១៨

៦"ការសងសំណងមិនគ្រប់ មានន័យថា បង្ខំជនរងផលប៉ះពាល់ ឱ្យធ្លាក់ចូលក្នុងអន្ទាក់បំណុល.... "កិច្ចពិភាក្សាក្នុងក្រុមគោលដៅ" បានបង្ហាញនូវបញ្ហាទាំងនេះ"។ សេចក្តីព្រាងរបាយការណ៍សវនកម្ម ចុះខែកក្កដា ឆ្នាំ២០០៥ កថាខ័ណ្ឌ ២១១ ទំព័រ៧២

### ឃ. ការវាយតម្លៃលើកិរិតលទ្ធភាពដោះស្រាយបញ្ហា

២៤. កិរិតលទ្ធភាព (ប្រូបាប៊ីលីតេ) ដែលថាបញ្ហារបស់ដើមបណ្តឹងអាចដោះស្រាយបាន តាមរយៈដំណើរការពិគ្រោះយោបល់ គឺហាក់ដូចជាពិបាកប៉ាន់ស្មានណាស់។ វេទិការដំណោះស្រាយមួយចំនួន ដែលអាចត្រូវបានមើលឃើញ (សូមអានកថាខណ្ឌទី២៥-២៦ខាងក្រោម) អាចបង្ហាញឱ្យឃើញថា អាចមានដំណោះស្រាយប្រកបដោយលទ្ធផលវិជ្ជមាន។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង គណៈកម្មការអន្តរក្រសួងសម្រាប់ដោះស្រាយផលប៉ះពាល់ មានជឿថា ក្រសួង និងគណៈកម្មការ អាចដោះស្រាយបញ្ហាដែលនៅសេសសល់ទាំងឡាយបាន ដោយមិនចាំបាច់ប្រើប្រាស់ដំណើរការពិគ្រោះយោបល់របស់ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស ទេ។ ការប្តេជ្ញាចិត្តរបស់ស្ថាប័នទាំងពីរនេះ និង របស់និវាសនដ្ឋានបេសសកម្មប្រចាំកម្ពុជា (CARM) ចំពោះដំណើរការពិគ្រោះយោបល់ គឺត្រូវការជាចាំបាច់ ប្រសិនបើចង់ឱ្យការដោះស្រាយបញ្ហាទាំងនេះប្រកបដោយជោគជ័យ។ ទោះជាយ៉ាងណា ក៏ហាក់ដូចជាមានមូលដ្ឋាន និងសារប្រយោជន៍ក្នុងការបន្តដំណើរការពិគ្រោះយោបល់នេះតទៅទៀត។

## ៣. អនុសាសន៍ និងសំណើវិធានការសកម្មភាពដែលគួរអនុវត្ត

### ក. សកម្មភាពដំណោះស្រាយ និងអនុសាសន៍

**២៥. ប័ណ្ណកម្មសិទ្ធិដីធ្លី :** ដើមបណ្តឹងមានជំនឿថា ប្រសិនបើគ្មានប័ណ្ណកម្មសិទ្ធិលើដីធ្លីទេ ពួកគាត់ប្រឈមទៅនឹងការបាត់បង់ដីធ្លី ដោយសារការដណ្តើមយកផលប្រយោជន៍ពីចំណោមអ្នកមានអំណាច។ ហេតុនេះ ការទទួលបានប័ណ្ណកម្មសិទ្ធីដីធ្លី គឺជាមធ្យោបានដោះស្រាយមួយ ក្នុងចំណោមមធ្យោបាយដោះស្រាយសំខាន់នានា ដែលដើមបណ្តឹងទាំងនោះស្វែងរកក្នុងដំណើរការពិគ្រោះយោបល់។ ចាប់តាំងពីឆ្នាំ២០០២មកម្លេះ អង្គការមិនមែនរដ្ឋាភិបាល និង ជនរងផលប៉ះពាល់ បាននិងកំពុងលើកឡើងអំពីសេចក្តីថែងក្នុងផែនការស្តីពីការដោះស្រាយផលប៉ះពាល់ (RRP) ថា ប័ណ្ណកម្មសិទ្ធិដីធ្លីនឹងផ្តល់ជូនដល់ជនរងផលប៉ះពាល់ (សូមមើលកថាខណ្ឌ ២២ ខាងលើ) ដែលដាក់កាតព្វកិច្ចចំពោះធនាគារអភិវឌ្ឍន៍អាស៊ី ក្នុងការធ្វើឱ្យប្រាកដថា ជនរងផលប៉ះពាល់ ពីការអភិវឌ្ឍផ្លូវនេះ ទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីនៅកន្លែងផ្លាស់ប្តូរទីតាំងនោះ។ អង្គការក្រៅរដ្ឋាភិបាល ក៏បានលើកឡើងពីគម្រោងជាក់លាក់មួយចំនួនផ្សេងទៀត ដែលមានការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីដល់ជនដែលត្រូវផ្លាស់ប្តូរទីតាំងថ្មី ក្នុងលក្ខណៈឆាប់រហ័ស។

**២៦. ភាពក្រីក្រចុះដុនដាប :** ដើមបណ្តឹងយល់ឃើញថា ជីវភាពរស់នៅរបស់ខ្លួនកាន់តែមានចុះដុនដាប ចាប់តាំងពីមករស់នៅប្រើប្រាស់ដីធ្លីនៅកន្លែងថ្មី ដោយសារការបាត់បង់ប្រភពចំណូលសម្រាប់ចិញ្ចឹមជីវិតដែលខ្លួនធ្លាប់មានពីមុន ហើយមានករណីជាច្រើន ពួកគាត់បានធ្លាក់ខ្លួនក្នុងអន្ទ្រាក់បំណុល បណ្តាលមកពីការផ្តល់សំណងយឺតយ៉ាវ។ ដើមបណ្តឹង

យល់ឃើញផងដែរថា ខ្លួនគួរសាកសមទទួលបាន កម្មវិធីផ្តល់មុខរបរចិញ្ចឹមជីវិត ដើម្បីស្រង់ពួកគាត់ឱ្យផុតពីភាពក្រីក្រ ចុះដុនដាបនោះ និងវិលទៅរកស្ថានភាពជីវភាពដូចមុនពេលចាប់ផ្តើមគម្រោងវិញ ហើយថាកម្មវិធីផ្តល់មុខរបរចិញ្ចឹមជីវិតនេះទៀតសោតត្រូវបញ្ចូលនូវមធ្យោបាយ ដែលអាចជួយពួកគាត់ឱ្យរួចផុត ពីបន្ទុកបំណុលដ៏សាហាវនោះផង។ ដើមបណ្តឹងក៏បានស្នើឱ្យរៀបចំការអង្កេតផងដែរ។ គួរមានការពិនិត្យពីជម្រើសមធ្យោបាយក្នុងការផ្តល់កម្មវិធីសម្រាប់ទ្រទ្រង់ជីវភាពរស់នៅ និងការរំលោះបំណុល និងដាក់ចេញនូវវិធីសាស្ត្រដោះស្រាយសមស្រប។ ចំណុចនេះ អាចត្រូវការធនធានបន្ថែមទៀត រួមទាំងការឧបត្ថម្ភគាំទ្រដល់ជនរងផលប៉ះពាល់ដែលជាដើមបណ្តឹងនីមួយៗជាដើម។

## ខ. សំណើរវិធានការសកម្មភាពដែលគួរអនុវត្ត

២៧. ក្នុងស្ថានភាពបែបនេះ មធ្យោបាយល្អបំផុតនោះគឺការបន្តអនុវត្តតាមជំហានទាំងឡាយនៃដំណើរការពិគ្រោះយោបល់ ដោយមានចំណុច ត្រូវសម្រេចចិត្តសំខាន់ៗ ២គឺ : សម្រាប់ដើមបណ្តឹង គួរអនុវត្តជំហានទី ៥ ហើយសម្រាប់ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស គួរអនុវត្តជំហានទី ៦ (សូមមើលឧបសម្ព័ន្ធទី១)។ ជាផ្នែកមួយនៃការត្រួតពិនិត្យ និងវាយតម្លៃនេះ (ជំហានទី ៤ នៃដំណើរការ) ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស នឹងត្រូវផ្តល់របាយការណ៍នេះ ជាភាសាអង់គ្លេស និងភាសាខ្មែរ ដល់ដើមបណ្តឹង និងនិវាសនដ្ឋានបេសកកម្មប្រចាំប្រទេសកម្ពុជា ដោយមានការពន្យល់ដល់ដើមបណ្តឹងថា ពួកគាត់ត្រូវសម្រេចចិត្តថាតើចង់បន្តដំណើរការពិគ្រោះយោបល់ ឬ សម្រេចបញ្ឈប់ដំណើរការពិគ្រោះយោបល់នេះ ប្រសិនបើពួកគាត់យល់ឃើញថាដំណើរការនោះនឹងមិនចំគោលបំណងឡើយ (ហើយក្នុងករណីសម្រេចបញ្ឈប់ដំណើការពិគ្រោះយោបល់ ពួកគាត់អាចរៀបចំឯកសារស្នើសុំឱ្យមានការពិនិត្យលើអនុលោមភាព ប្រសិនបើដើមបណ្តឹងមានបំណងប្តឹងបន្ត។ និវាសនដ្ឋានបេសកកម្មប្រចាំប្រទេសកម្ពុជា និងទាំងដើមបណ្តឹង អាចធ្វើការបញ្ជាក់លើបញ្ហាមួយចំនួនជាមួយនឹង ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស មុននឹងចាប់ផ្តើមផ្តល់យោបល់ និងធ្វើសេចក្តីសម្រេចចិត្ត។ តាមពិត និវាសនដ្ឋានបេសកកម្មប្រចាំប្រទេសកម្ពុជា អាចទំនាក់ទំនងជាមួយ ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស បានយ៉ាងងាយ តាមរយៈទូរស័ព្ទទូរសារ អ៊ីមែល ឬ ការពិភាក្សាដោយផ្ទាល់តាមបណ្តាញអ៊ិនធើរណេត ប៉ុន្តែការទំនាក់ទំនងជាមួយដើមបណ្តឹងវិញមានការលំបាកច្រើន។ យោងតាមគោលការណ៍ របស់ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស អំពីការប្រព្រឹត្តិដោយស្មើភាពគ្នាលើគ្រប់ភាគីទាំងអស់ ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស នឹងត្រូវធ្វើឱ្យប្រាកដថា ដើមបណ្តឹងទទួលបានស្ថានភាពក្នុងកម្រិតប្រហាក់ប្រហែលគ្នា ពោលគឺ ដើមបណ្តឹងត្រូវការយល់ច្បាស់អំពីខ្លឹមសារនៃរបាយការណ៍នេះ មានឱកាសក្នុងការសួរបញ្ជាក់ និងទទួលបាននូវការផ្តល់យោបល់ប្រឹក្សាប្រកបដោយឯករាជ្យ និងអព្យាក្រឹតទៅលើផលវិបាកនានានៃការធ្វើសម្រេចចិត្តរបស់ខ្លួន។ ហេតុដូចនេះ ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស

មានផែនការផ្តល់ទីប្រឹក្សាឯករាជ្យដល់ដើមបណ្តឹង។ ប្រសិនបើ ដើមបណ្តឹងសម្រេចចិត្តថាបន្តដំណើរការពិគ្រោះយោបល់នេះទៀត ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស នឹងស្នើសុំឱ្យដើមបណ្តឹង និងនិវាសនដ្ឋានបេសសកកម្មប្រចាំប្រទេសកម្ពុជា ផ្តល់យោបល់ លើលទ្ធផលរកឃើញរបស់ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេសដូចមានរៀបរាប់ក្នុងរបាយការណ៍នេះ (ជំហានទី៥ នៃដំណើរការពិគ្រោះយោបល់)។ ជាថ្មីម្តងទៀត ដើមបណ្តឹងអាចត្រូវការឱ្យមានទីប្រឹក្សាឯករាជ្យជួយពួកគាត់ក្នុងការរៀបចំយោបល់របស់ខ្លួន។ នៅពេលទទួលបានយោបល់ ពីភាគីទាំងពីរ និង ដោយមានការឯកភាពពីដើមបណ្តឹង និង និវាសនដ្ឋានបេសកកម្មប្រចាំប្រទេសកម្ពុជា ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស ក៏អាចផ្ញើរបាយការណ៍នេះ ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ/គណៈកម្មការអន្តរក្រសួងសម្រាប់ដោះស្រាយផលប៉ះពាល់គម្រោង ដើម្បីផ្តល់យោបល់ផងដែរ។ ផ្អែកលើខ្លឹមសារនៃការឆ្លើយតបនានាការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស អាចធ្វើការវាយតម្លៃសាជាថ្មីនូវកំរិតលទ្ធភាពជោគជ័យនៃដំណើរការពិគ្រោះយោបល់ នៅក្នុងជំហានបន្ទាប់ (គឺជំហានទី៦ នៃដំណើរការពិគ្រោះយោបល់) ដោយផ្អែកលើការវាយតម្លៃនោះ។ នៅក្នុងជំហានទី៦ ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស អាចផ្តល់អនុសាសន៍ដល់ប្រធានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ថា : (i) គួរបន្តដំណើរការពិគ្រោះយោបល់ និងការរៀបចំដាក់ចេញនូវវិធានការសកម្មភាពក្នុងការពិភាក្សាពិគ្រោះយោបល់ជាមួយដើមបណ្តឹង និវាសនដ្ឋានបេសកកម្មប្រចាំប្រទេសកម្ពុជា និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ/គណៈកម្មការអន្តរក្រសួងសម្រាប់ដោះស្រាយផលប៉ះពាល់គម្រោង ឬ (ii) គួរធ្វើការបញ្ចប់ដំណើរការពិគ្រោះយោបល់នេះ ពីព្រោះដំណើរការត្រួតពិនិត្យបន្ថែមទៀតណាមួយនោះនឹងមិនចំគោលបំណងនៃការដោះស្រាយបញ្ហាបណ្តឹងនេះឡើយ។ ឧបសម្ព័ន្ធ ២ បង្ហាញព័ត៌មានលំអិត អំពីជំហានទី៤ ដល់ទី៨ និង តារាងពេលវេលា។

២៨. ប្រសិនបើមានសេចក្តីសម្រេចថាត្រូវបន្តដំណើរការពិគ្រោះយោបល់ ហើយព្រមទទួលយកការសម្របសម្រួលរបស់ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេសលើករណីក្នុងប្រទេសកម្ពុជានេះ បុគ្គលិកការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស នឹងអនុវត្តតួនាទីជាភាគីសម្របសម្រួល។ ប្រសិនបើអ្នកពាក់ព័ន្ធទាំងឡាយមិនព្រមទទួលយកការបន្តសកម្មភាពរបស់ ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេសទេ ប៉ុន្តែនៅតែចង់បន្តអនុវត្តដំណើរការពិគ្រោះយោបល់នោះ ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស អាចជួយណែនាំនិងជ្រើសរើសអ្នកសម្របសម្រួលផ្សេងទៀត ដែលអ្នកពាក់ព័ន្ធអាចទទួលយកបាន។ ក្នុងករណីណាក៏ដោយ ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស ឬ ក្រុមអ្នកសម្របសម្រួលផ្សេងទៀត អាចរៀបចំផែនការប្រជុំរួមគ្នាមួយចំនួន (រួមទាំងការធ្វើទស្សនកិច្ចសិក្សានៅតាមទីកន្លែងជាក់ស្តែង ក្នុងករណីចាំបាច់) ជាមួយអ្នកពាក់ព័ន្ធទាំងឡាយ ហើយ ធ្វើការរៀបចំ

និងសម្របសម្រួលកិច្ចប្រជុំទាំងនោះ។ ខាងក្រោមនេះជាជំហានចាំបាច់មួយចំនួន ដែលត្រូវអនុវត្តក្នុងការរៀបចំកិច្ចប្រជុំ ៖

១. កំណត់ឱ្យដឹងថាអ្នកពាក់ព័ន្ធណាខ្លះដែលគួរចូលរួមក្នុងកិច្ចប្រជុំណាមួយ និងធ្វើការស្វែងយល់ពីការយល់ដឹងរបស់អ្នកពាក់ព័ន្ធនោះទាក់ទងនឹងស្ថានភាព តួនាទី ការទទួលខុសត្រូវ និងការរំពឹងទុករបស់អ្នកពាក់ព័ន្ធនោះ។

២. ស្វែងយល់ពីការត្រៀមខ្លួនជាមុនរបស់អ្នកពាក់ព័ន្ធក្នុងការជួបប្រជុំ ស្វែងយល់ពីលក្ខខណ្ឌ ដែលអ្នកពាក់ព័ន្ធត្រូវបំពេញមុនពេលចូលប្រជុំ និង វិធានផ្ទៃក្នុងសម្រាប់ការប្រជុំ ដែលអ្នកពាក់ព័ន្ធមានបំណងចង់ប្រើប្រាស់អនុវត្តនៅក្នុងដំណើរការពិគ្រោះយោបល់ (ឧបសម្ព័ន្ធ ៣ បង្ហាញពី គំរូនៃវិធានផ្ទៃក្នុងសម្រាប់ការប្រជុំពិភាក្សា)។

៣. លើកសំណើអំពីលំដាប់លំដោយនៃកិច្ចប្រជុំជាបន្តបន្ទាប់ ដើម្បីឱ្យអ្នកពាក់ព័ន្ធទាំងឡាយអាចឈានទៅឯកភាពព្រមព្រៀងលើវិធីសាស្ត្រដោះស្រាយបញ្ហានានា ដែលបានលើកឡើងដោយដើមបណ្តឹង។ សំណើនេះអាចមានបញ្ចូលនូវចំនុចដូចតទៅ ៖ គោលបំណងនៃកិច្ចប្រជុំ របៀបវារៈនៃកិច្ចប្រជុំ និងដំណើរការប្រជុំ អ្នកចូលរួម ការប៉ាន់ស្មានពេលវេលា (ថាតើត្រូវមានការប្រជុំចាំបាច់ប៉ុន្មានដង ការប្រជុំនីមួយៗត្រូវការរយៈពេលប៉ុន្មាន ការប្រជុំត្រូវរៀបចំនៅពេលណាដែលសមស្រប សម្រាប់ភាគីពាក់ព័ន្ធផ្សេងៗ) បរិយាកាសកន្លែងប្រជុំដែលមានលក្ខណៈអំណោយផល (ឧទាហរណ៍ កន្លែងស្ងាត់ ដែលអ្នកចូលរួម មានអារម្មណ៍កក់ក្តៅ) អ្នកបកប្រែឯកសារ អ្នកបកប្រែផ្ទាល់មាត់ ការរៀបចំរបាយការណ៍ (កំណត់ហេតុប្រជុំ) និងការរៀបចំឯកសារឧបករណ៍ជំនួយសម្រាប់ការប្រជុំ។

២៩. ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស អាចចេញចំណាយសម្រាប់ទីប្រឹក្សារបស់ដើមបណ្តឹង ចំណាយលើអ្នកសម្របសម្រួល អ្នកបកប្រែឯកសារ អ្នកបកប្រែផ្ទាល់មាត់ ការធ្វើដំណើររបស់ដើមបណ្តឹង កន្លែងប្រជុំប្រកបដោយភាពកក់ក្តៅ អាហារ និងទូទាត់សមស្របសម្រាប់ការបាត់បង់ចំណូលរបស់ដើមបណ្តឹង ដោយសាររវល់មកចូលរួមប្រជុំ។ ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស មិនចេញចំណាយរបស់និវាសនដ្ឋានបេសសកកម្មប្រចាំប្រទេសកម្ពុជា ឬ ចំណាយរបស់រដ្ឋាភិបាលឡើយ។ ជាញឹកញាប់ អង្គការមិនមែនរដ្ឋាភិបាលដែលចូលរួមក្នុងកិច្ចប្រជុំ មិនទាមទារការទូទាត់ចំណាយនៃសកម្មភាពខ្លួនឡើយ ព្រោះការទាមទារណាមួយនោះ អាចជះឥទ្ធិពលដល់ភាពឥតលំអៀងរបស់ខ្លួន។

# ដំណាក់កាលនានានៃដំណើរការពិគ្រោះយោបល់

**ជំហានទី ១ : ការដាក់ពាក្យបណ្តឹង**

- ពាក្យបណ្តឹងត្រូវដាក់ជូនអ្នកសម្របសម្រួលគម្រោងពិសេស ឬ ត្រូវបញ្ជូនទៅអ្នកសម្របសម្រួលគម្រោងពិសេស ប្រសិនបើផ្នែកគ្រប់គ្រង ឬ ផ្នែកណាមួយនៅការិយាល័យកណ្តាលរបស់ធនាគារអភិវឌ្ឍន៍អាស៊ី បានទទួលពាក្យបណ្តឹងនោះ ។

↓

រយៈពេល ៧ ថ្ងៃ បន្ទាប់ពីទទួលពាក្យបណ្តឹង

**ជំហានទី ២ : ការចុះបញ្ជី និងការបញ្ជាក់ពីការបានទទួលពាក្យបណ្តឹង**

- អ្នកសម្របសម្រួលគម្រោងពិសេស នឹងចុះបញ្ជីពាក្យបណ្តឹងក្នុងបញ្ជីពាក្យបណ្តឹង ហើយផ្ញើលិខិតបញ្ជាក់ពីការបានទទួលពាក្យបណ្តឹងទៅដើមបណ្តឹង ដោយចំលងពាក្យបណ្តឹងនោះមួយច្បាប់ជូនទៅផ្នែកគ្រប់គ្រងរបស់ធនាគារ ។
- ប្រសិនបើអ្នកសម្របសម្រួលគម្រោងសម្រេចថាពាក្យបណ្តឹងមិនអាចទទួលយកបាន ដោយសារមិនស្ថិតនៅក្រោមអាណត្តិរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ឬ អ្នកសម្របសម្រួលមិនអាចជួយដោះស្រាយបញ្ហាបាននោះ អ្នកសម្រប សម្រួលនឹងជូនដំណឹងដល់ដើមបណ្តឹង ដោយចំលងពាក្យបណ្តឹងនោះមួយច្បាប់ជូនទៅផ្នែកគ្រប់គ្រងរបស់ធនាគារ ។

↓

រយៈពេល ២១ថ្ងៃ បន្ទាប់ពីទទួលពាក្យបណ្តឹង

**ជំហានទី ៣ : ការកំណត់ពីលក្ខណៈសម្បត្តិនៃពាក្យបណ្តឹង**

- អ្នកសម្របសម្រួលគម្រោងពិសេស នឹងធ្វើការពិនិត្យមើលពាក្យបណ្តឹង ដើម្បីកំណត់ពីលក្ខណៈសម្បត្តិអាចទទួលយកបាននៃពាក្យបណ្តឹងនោះ ។
- ការងារកំណត់ពីលក្ខណៈសម្បត្តិនៃពាក្យបណ្តឹង អាចផ្អែកលើលទ្ធផលនៃការពិនិត្យមើលឯកសារដែលមានក្នុងការិយាល័យ និង/ឬ ចុះពិនិត្យនៅតាមកន្លែងជាក់ស្តែង ។
- ប្រសិនបើអ្នកសម្របសម្រួលគម្រោង បដិសេធពាក្យបណ្តឹង អ្នកសម្របសម្រួលគម្រោងពិសេសនឹងជូនដំណឹងដល់ដើមបណ្តឹង ពីមូលហេតុ ដែលពាក្យបណ្តឹងមិនមានលក្ខណៈសម្បត្តិអាចទទួលយកបាន ហើយក៏ជូនដំណឹងដល់ដើមបណ្តឹង ផងដែរថា ដើមបណ្តឹងអាច ស្នើសុំឱ្យមានការត្រួតពិនិត្យអនុលោមភាព ដោយដាក់ពាក្យសុំទៅការិយាល័យនៃក្រុមពិនិត្យអនុលោមភាព ប្រសិនបើដើមបណ្តឹងចង់សុំ ។

→ បន្ទាប់ពីការជូនដំណឹងរបស់អ្នកសម្របសម្រួល គម្រោងថាពាក្យបណ្តឹងមិនអាចទទួលយកបាន នោះដើមបណ្តឹងអាចដាក់ស្នើសុំការត្រួតពិនិត្យ អនុលោមភាព ប្រសិនបើដើមណ្តឹងមានបំណង

↓

រយៈពេល ៤៩ថ្ងៃ បន្ទាប់ពីទទួលពាក្យបណ្តឹង

**ជំហានទី ៤ : ការត្រួតពិនិត្យ និងវាយតម្លៃពាក្យបណ្តឹង**

- ប្រសិនបើពាក្យបណ្តឹងមានលក្ខណៈអាចទទួលយកបាន អ្នកសម្របសម្រួលគម្រោងពិសេស នឹងធ្វើការត្រួតពិនិត្យ និងវាយតម្លៃពាក្យបណ្តឹងនោះ ។
- ការត្រួតពិនិត្យ ជាធម្មតារួមមានការចុះពិនិត្យតាមទីកន្លែងជាក់ស្តែង ការសម្ភាស និងការជួបពិភាក្សាជាមួយដើមបណ្តឹង និងជាមួយភ្នាក់ងារប្រតិបត្តិគម្រោង ឬ រដ្ឋាភិបាលនៃប្រទេសកំពុងអភិវឌ្ឍន៍ ដែលជាសមាជិក ឬ ជាមួយម្ចាស់ជំនួយគម្រោងឯកជន ក៏ដូចជាអ្នកពាក់ព័ន្ធផ្សេងៗទៀត ដែលអ្នកសម្របសម្រួលគម្រោងពិសេស យល់ថាមានសារៈសំខាន់ ។
- អ្នកសម្របសម្រួលគម្រោងពិសេស នឹងប្រមូលព័ត៌មានពី នាយកដ្ឋានប្រតិបត្តិការ ហើយប្រសិនបើចាំបាច់ នឹងស្នើសុំយោបល់ និង ការឧបត្ថម្ភគាំទ្រ ។
- អ្នកសម្របសម្រួលគម្រោងពិសេស នឹងធ្វើការពិនិត្យឯកសារព័ត៌មានពាក់ព័ន្ធ និងចុះបេសកកម្ម ដើម្បីស្វែងរកការពិតផ្អែកលើគំនិតផ្តួចផ្តើមផ្ទាល់ខ្លួន ឬ ដោយមានកិច្ចពិភាក្សាជាមួយនាយកដ្ឋានប្រតិបត្តិការ ចូលរួមក្នុងក្រុមបេសកកម្មពិសេសសម្រាប់រដ្ឋបាលកិច្ចគម្រោងរបស់នាយកដ្ឋានប្រតិបត្តិការ ។
- អ្នកសម្របសម្រួលគម្រោងពិសេស នឹងបញ្ចប់ការត្រួតពិនិត្យ និងវាយតម្លៃរបស់ខ្លួន ហើយរាយការណ៍ជូនទៅប្រធាន របស់ធនាគារអភិវឌ្ឍន៍អាស៊ី ដោយចម្លងមួយច្បាប់ជូនអនុប្រធានពាក់ព័ន្ធ ។
- អ្នកសម្របសម្រួលគម្រោងពិសេស នឹងផ្ញើលទ្ធផលការរកឃើញរបស់ខ្លួនជូននាយកដ្ឋានប្រតិបត្តិការ និងដើមបណ្តឹងផងដែរ ។

↓

រយៈពេល ៧ថ្ងៃ បន្ទាប់ពីទទួលលទ្ធផលការរកឃើញរបស់អ្នកសម្របសម្រួលគម្រោងពិសេស

- អ្នកសម្របសម្រួលគម្រោងពិសេស នឹងជូនដំណឹងដល់ដើមបណ្តឹង នូវជម្រើស ២ ដូចតទៅ ទី ១ : ដើមបណ្តឹងអាចសម្រេចបន្តដំណើរការពិគ្រោះយោបល់ និងផ្តល់យោបល់លើការរកឃើញរបស់អ្នសម្របសម្រួលគម្រោងពិសេស (ដូចមានក្នុងជំហានទី ៥) ឬ ទី ២ : ដើមបណ្តឹងអាចសម្រេចប្រានចោលដំណើរការពិគ្រោះយោបល់ ប្រសិនបើដើមបណ្តឹងយល់ថាដំណើរការនេះមិនចំគោលបំណងនៃបណ្តឹង រួចដើមបណ្តឹងអាចស្នើសុំឱ្យមានការត្រួតពិនិត្យអនុលោមភាព ដោយផ្ញើសំណើទៅការិយាល័យនៃក្រុមពិនិត្យអនុលោមភាព ប្រសិនបើដើមបណ្តឹងមានបំណងប្តឹងបន្ត ។
- អ្នកសម្របសម្រួលគម្រោងពិសេស នឹងផ្តល់រយៈពេល ៧ថ្ងៃ ដល់ដើមបណ្តឹងចាប់ពីថ្ងៃទទួលលទ្ធផលការរកឃើញរបស់អ្នកសម្របសម្រួលគម្រោងពិសេស ដើម្បីឆ្លើយតបនឹងអ្នកសម្របសម្រួលគម្រោងពិសេស ដោយបញ្ជាក់ពីការសម្រេចចិត្តរបស់ដើមបណ្តឹង ។

→ ប្រសិនបើដើមបណ្តឹងយល់ឃើញថា ដំណើរការពិគ្រោះយោបល់មិនត្រូវតាមគោលបំណងទេនោះ ដើមបណ្តឹងអាចស្នើសុំការត្រួតពិនិត្យអនុលោមភាពទៅការិយាល័យក្រុមត្រួតពិនិត្យអនុលោមភាព ប្រសិនបើ

↓

រយៈពេល ១៤ថ្ងៃ បន្ទាប់ពីទទួលការជូនដំណឹងរបស់អ្នកសម្របសម្រួលគម្រោងពិសេស

**ជំហានទី ៥ : ការសម្រេចចិត្តរបស់ដើមបណ្តឹងក្នុងការបន្តដំណើរការពិគ្រោះយោបល់ ឬ ស្នើសុំការត្រួតពិនិត្យអនុលោមភាព**

- បន្ទាប់ពីទទួលបានការសម្រេចចិត្តរបស់ដើមបណ្តឹង ថាចង់បន្តដំណើរការពិគ្រោះយោបល់ និងផ្តល់យោបល់លើលទ្ធផលរកឃើញរបស់អ្នកសម្របសម្រួលគម្រោងពិសេស អ្នកសម្របសម្រួលនឹងជូនដំណឹងដល់នាយកដ្ឋានប្រតិបត្តិការ និង ដល់ដើមបណ្តឹង ថា មានរយៈពេល ១៤ ថ្ងៃ ចាប់ពីថ្ងៃទទួលការជូនដំណឹង ក្នុងការផ្តល់យោបល់ លើលទ្ធផលការរកឃើញរបស់អ្នកសម្របសម្រួល ។
- បន្ទាប់ពីទទួលបានការសម្រេចចិត្តរបស់ដើមបណ្តឹង ថាចង់ស្នើសុំការត្រួតពិនិត្យអនុលោមភាព អ្នកសម្របសម្រួលគម្រោងពិសេស នឹងត្រូវបិទពាក្យបណ្តឹង ។

ប្រសិនបើដើមបណ្តឹងយល់ ឃើញថាដំណើរការពិគ្រោះយោបល់នេះមិនត្រូវតាមគោលបំណងដើមបណ្តឹងអាច ដាក់ស្នើសុំការត្រួតពិនិត្យអនុលោមភាព ទៅការិយាល័យក្រុមត្រួតពិនិត្យអនុលោមភាព ប្រសិនបើដើមបណ្តឹងចង់ប្តឹងបន

រយៈពេល ៧ថ្ងៃ បន្ទាប់ពីទទួលបានយោបល់របស់នាយកដ្ឋានប្រតិបត្តិការ និងដើមបណ្តឹង

**ជំហានទី ៦ : យោបល់របស់នាយកដ្ឋានប្រតិបត្តិការ និងរបស់ដើមបណ្តឹង លើលទ្ធផលរកឃើញរបស់អ្នកសម្របសម្រួលគម្រោងពិសេស និងអនុសាសន៍របស់អ្នកសម្របសម្រួលគម្រោងពិសេស**

- នៅពេលទទួលយោបល់ពីនាយកដ្ឋានប្រតិបត្តិការ និងពីដើមបណ្តឹង លើលទ្ធផលរកឃើញរបស់អ្នកសម្របសម្រួលគម្រោងពិសេស ពេលនោះអ្នកសម្របសម្រួលនឹងធ្វើការពិចារណាយោបល់នោះ ព្រមទាំង ផ្តល់អនុសាសន៍ និងស្នើសុំការឯកភាពពីប្រធានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី លើសកម្មភាពណាមួយដូចតទៅ ទី១ : កំណត់ថាការត្រួតពិនិត្យបន្ថែមនឹងមិនត្រូវតាមគោលបំណង ហើយធ្វើការសម្រេចបញ្ចប់ដំណើរការពិគ្រោះយោបល់ ឬ ទី ២ : រៀបចំដាក់ចេញនូវសំណើ វិធានការសកម្មភាព ដោយមានការពិភាក្សាជាមួយនឹងដើមបណ្តឹង ជាមួយនាយកដ្ឋានប្រតិបត្តិការដែលពាក់ព័ន្ធ និង ជាមួយភ្នាក់ងារប្រតិបត្តិគម្រោង ឬ រដ្ឋាភិបាលប្រទេសកំពុងអភិវឌ្ឍន៍ ដែលជាសមាជិក ឬ ម្ចាស់ជំនួយគម្រោងឯកជន ដែលពាក់ព័ន្ធនឹងការផ្តល់ជំនួយរបស់ខ្លួន។

**ជំហានទី ៧ : ការអនុវត្តវិធានការសកម្មភាព ក្នុងដំណើរការពិគ្រោះយោបល់**

- អ្នកសម្របសម្រួលគម្រោងពិសេស នឹងអនុវត្តវិធានការសកម្មភាព ក្នុងដំណើរការពិគ្រោះយោបល់ ដោយមានការពិភាក្សាជាមួយដើមបណ្តឹង នាយកដ្ឋានប្រតិបត្តិការពាក់ព័ន្ធ និង ភ្នាក់ងារប្រតិបត្តិគម្រោង ឬ រដ្ឋាភិបាលប្រទេសកំពុងអភិវឌ្ឍន៍ ដែលជាសមាជិកឬ ម្ចាស់ជំនួយគម្រោងឯកជន។
- អ្នកសម្របសម្រួលគម្រោងពិសេសអាចជ្រើសរើសវិធីសាស្ត្រ ១ ឬ ច្រើន ក្នុងចំណោមវិធីសាស្ត្រមួយចំនួន ដូចជា : (i) បន្តការពិគ្រោះពិភាក្សាលើដំណើរការពិគ្រោះយោបល់ ដើម្បីស្វែងរកដំណោះស្រាយ ដែលអាចទទួលយកបានទាំងសងខាងជាមួយដើមបណ្តឹង ទី (ii) សម្របសម្រួលដំណើរការពិគ្រោះយោបល់ ដោយបង្កើតវេទិកាមួយតាមរយៈសុន្ទនៈនៃការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស រវាងដើមបណ្តឹង និងភ្នាក់ងារប្រតិបត្តិគម្រោង ឬ រដ្ឋាភិបាលប្រទេសកំពុងអភិវឌ្ឍន៍ ដែលជាសមាជិក ឬ ម្ចាស់ជំនួយគម្រោងឯកជន និង (iii) សម្របសម្រួលឱ្យមានការបង្កើតឡើងយន្តការសម្រុះសម្រួលគ្នាមួយ ។
- ពេលដំណើរការពិគ្រោះយោបល់ដែលប្រើប្រាស់ការពិគ្រោះពិភាក្សា និង/ឬ សុន្ទនៈនៃការិយាល័យ ត្រូវចប់សព្វគ្រប់ អ្នកសម្របសម្រួលគម្រោងពិសេស នឹងបញ្ជូនរបាយការណ៍ ដែលរួមបញ្ចូល កិច្ចព្រមព្រៀងលើការដោះស្រាយបញ្ហា (ប្រសិនបើមាន) ស្របទៅតាមនីតិវិធីរបស់ ធនាគារអភិវឌ្ឍន៍អាស៊ី ជូនប្រធានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដោយមានអនុសាសន៍ ដែលមានការឯកភាពពីដើមបណ្តឹង នាយកដ្ឋានប្រតិបត្តិការពាក់ព័ន្ធ និង ភ្នាក់ងារប្រតិបត្តិគម្រោង ឬ រដ្ឋាភិបាលប្រទេសកំពុងអភិវឌ្ឍន៍ ដែលជាសមាជិក ឬម្ចាស់ជំនួយគម្រោងឯកជន។ អ្នកសម្របសម្រួលគម្រោងពិសេសនឹងចេញរបាយការណ៍មួយ ដែលបញ្ចូលនូវសេចក្តីសម្រេចរបស់ ប្រធានធនាគារអភិវឌ្ឍន៍អាស៊ី លើអនុសាសន៍នោះ ហើយផ្ញើជូនដើមបណ្តឹង ភ្នាក់ងារប្រតិបត្តិគម្រោង ឬរដ្ឋាភិបាលប្រទេសកំពុងអភិវឌ្ឍន៍ ដែលជាសមាជិក ឬម្ចាស់ជំនួយគម្រោងឯកជន និង ក្រុមប្រឹក្សាភិបាលធនាគារ សម្រាប់ជ្រាបជាព័ត៌មាន។
- នៅពេលដំណើរការពិគ្រោះយោបល់ ដែលប្រើប្រាស់វិធីសាស្ត្រសម្រុះសម្រួល ត្រូវបានបញ្ចប់ អ្នកសម្រុះសម្រួលត្រូវផ្តល់របាយការណ៍របស់ខ្លួនទៅអ្នកសម្របសម្រួលគម្រោងពិសេស។ អ្នកសម្របសម្រួលគម្រោងពិសេស នឹងផ្ញើរបាយការណ៍នោះជូនទៅប្រធានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី សម្រាប់ជូនជាព័ត៌មាន ដោយថតចម្លងមួយច្បាប់ជូនក្រុមប្រឹក្សាភិបាលធនាគារ។
- ប្រសិនបើអ្នកសម្របសម្រួលគម្រោងពិសេស កំណត់ថា ការពិគ្រោះយោបល់បន្ថែមនឹងមិនត្រូវតាមគោលបំណងទេនោះ អ្នកសម្របសម្រួលគម្រោងពិសេស នឹងបញ្ជូនរបាយការណ៍ ជូនប្រធានធនាគារ ដោយធ្វើការសង្ខេបនូវពាក្យបណ្តឹង បង្ហាញពីជំហានដែលបានអនុវត្តដើម្បីដោះស្រាយបញ្ហាក្នុងពាក្យបណ្តឹង និងផ្តល់អនុសាសន៍។ របាយការណ៍ចុងក្រោយ ដែលបញ្ចូលសេចក្តីសម្រេចរបស់ប្រធានធានាគារអភិវឌ្ឍន៍អាស៊ី លើអនុសាសន៍ នឹងត្រូវផ្ញើជូនដើមបណ្តឹង ភ្នាក់ងារប្រតិបត្តិគម្រោង ឬរដ្ឋាភិបាលប្រទេសកំពុងអភិវឌ្ឍន៍ ដែលជាសមាជិក ឬម្ចាស់ជំនួយគម្រោងឯកជន និងក្រុមប្រឹក្សាភិបាលធនាគារ សម្រាប់ជ្រាបជាព័ត៌មាន។ នៅពេលបញ្ជូនទៅក្រុមប្រឹក្សាភិបាលធនាគារ របាយការណ៍ចុងក្រោយនោះ នឹងត្រូវចែកជូនសាធារណជន។

ប្រសិនបើដើមបណ្តឹងយល់ឃើញថា ដំណើរការត្រូវតាមគោលបំណង ប៉ុន្តែ មានការព្រួយបារម្ភខ្លាំងលើបញ្ហា អនុលោមភាព ដើមបណ្តឹងអាចស្នើសុំការត្រួតពិនិត្យអនុលោមភាព នៅខណៈពេលកំពុងអនុវត្តវិធានការសកម្មភាព

ប្រសិនបើដើមបណ្តឹងយល់ ឃើញថា ដំណើរការពិគ្រោះយោបល់ <u>មិនត្រូវតាមគោល បំណង</u> ហើយ ដើមបណ្តឹងចង់ប្តឹងបន្ត ដើមបណ្តឹងអាចស្នើសុំការត្រួតពិនិត្យអនុលោមភាព ដោយផ្ញើសំណើទៅការិយាល័យក្រុមត្រួតពិនិត្យ អនុលោមភាព

**ជំហានទី ៨ : ការបញ្ចប់ដំណើរការពិគ្រោះយោបល់**

- គ្រប់ភាគីពាក់ព័ន្ធទាំងអស់នៃដំណើរការពិគ្រោះយោបល់ លើកលែងតែ អ្នកសម្របសម្រួលគម្រោងពិសេស អាច "ដើរចេញពី" ដំណើរការពិគ្រោះយោបល់នេះ ប្រសិនបើគ្មានការមូលមតិគ្នាអំពីវិធានសកម្មភាពដែល ធ្វើបន្តទេនោះ ឬប្រសិនបើការអនុវត្តវិធានការសកម្មភាពនោះមិនស្របតាមទស្សនៈសមហេតុសមផលរបស់ អ្នកសម្របសម្រួលគម្រោងពិសេស ។ ការបញ្ចប់នូវការសម្រុះសម្រួល គឺត្រូវផ្អែកតាមបទដ្ឋាននៃនីតិវិធីសម្រុះសម្រួល ។

តារាងបង្ហាញជំហាននានាខាងលើនេះ ដកស្រង់ចេញពីឯកសារនីតិវិធីរបស់ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស ដែលអាចរកមើលឃើញនៅតាមវែបសៃត៍របស់ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស គឺ :
www.adb.org/SPF/Documents/ospf_operating_proc.pdf#page=18

# ដំណើរការពិគ្រោះយោបល់ និងតារាងពេលវេលា

## ជំហានទី ៤ : ការត្រួតពិនិត្យ និងវាយតម្លៃ

| | |
|---|---|
| របាយការណ៍ត្រួតពិនិត្យ និងវាយតម្លៃ ជាភាសាអង់គ្លេស | ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ |
| បកប្រែរបាយការណ៍ជាភាសាខ្មែរ ប្រហែលត្រូវចប់ក្នុងរយៈពេល ៧ថ្ងៃ | ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៧ |
| ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស ផ្ញើរបាយការណ៍ការត្រួតពិនិត្យ និងវាយតម្លៃ ជូនទៅប្រធានធនាគារអភិវឌ្ឍន៍អាស៊ី ដោយចម្លងជូនអនុប្រធានធានាគារអភិវឌ្ឍន៍អាស៊ី ដើមបណ្តឹង និងនិវាសនដ្ឋានបេសកកម្មប្រចាំប្រទេសកម្ពុជា | ប្រហែលថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៧ *កំណត់សម្គាល់ : រដ្ឋាភិបាលមិនទទួលបានរបាយការណ៍ទេ នៅដំណាក់កាលនេះទេ* |
| ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស ផ្តល់ទីប្រឹក្សាឯករាជ្យដើម្បីជួយពន្យល់អំពីខ្លឹមសារនៃរបាយការណ៍ដល់សហគមន៍ពាក់ព័ន្ធ | ថ្ងៃទី៥-៩ ខែវិច្ឆិកា ឆ្នាំ២០០៧ |

## ជំហានទី ៥ : ការសម្រេចចិត្តរបស់ដើមបណ្តឹងលើការបន្តដំណើរការពិគ្រោះយោបល់ ឬ ដាក់សំណើសុំការត្រួតពិនិត្យអនុលោមភាព - យោងតាមគោលនយោបាយរបស់ធនាគារមានរយៈពេល៧ថ្ងៃ

| | |
|---|---|
| ដើមបណ្តឹងសម្រេចចិត្តបន្តដំណើរការពិគ្រោះយោបល់ | ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៧ |
| អង្គការមិនមែនរដ្ឋាភិបាល ជូនដំណឹងអំពីការសម្រេចចិត្តរបស់ដើមបណ្តឹង ទៅការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស ជាភាសាខ្មែរ តាមរយៈ អ៊ីមេល៍ | ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៧ |
| ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស ទទួលបានការបកប្រែលិខិតជូនដំណឹង ហើយផ្តល់ដំណឹងទៅនិវាសនដ្ឋានបេសកកម្មប្រចាំប្រទេសកម្ពុជា | ជាបន្ទាន់ |
| និវាសនដ្ឋានបេសកកម្មប្រចាំប្រទេសកម្ពុជា ជូនដំណឹងដល់ រដ្ឋាភិបាលពីការសម្រេចចិត្តរបស់ដើមបណ្តឹងក្នុងការបន្តដំណើរការពិគ្រោះយោបល់ | បន្ទាប់ទទួលបានព័ត៌មានពីការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស |
| ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស ផ្ញើរបាយការណ៍ត្រួតពិនិត្យ និងវាយតម្លៃ ជូនទៅរដ្ឋាភិបាល ប្រសិនបើ រដ្ឋាភិបាលបង្ហាញនូវចំណាប់អារម្មណ៍ចង់បានរបាយការណ៍នោះ ហើយ និវាសនដ្ឋានបេសកកម្មប្រចាំប្រទេសកម្ពុជា និងដើមបណ្តឹង ផ្តល់ការឯកភាពឱ្យជូនរបាយការណ៍នោះ។ | បន្ទាប់ពីទទួលបានការឯកភាព |

**ជំហានទី ៦ : - ការផ្តល់យោបល់លើលទ្ធផលរកឃើញរបស់អ្នកសម្របសម្រួលគម្រោងពិសេស ដោយនាយកដ្ឋានប្រតិបត្តិការ និងដោយដើមបណ្តឹង** - រយៈពេល ១៤ ថ្ងៃ

**- ការផ្តល់អនុសាសន៍របស់អ្នកសម្របសម្រួលគម្រោងពិសេស ជូនប្រធានធានាគារអភិវឌ្ឍន៍អាស៊ី** - រយៈពេល ៧ថ្ងៃបន្ទាប់ពីទទួលបានយោបល់នានា

| | |
|---|---|
| ដើមបណ្តឹងផ្តល់យោបល់លើរបាយការណ៍ | ថ្ងៃទី៣០ វិច្ឆិកា ២០០៧ |
| ទីប្រឹក្សាឯករាជ្យ ជួយដើមបណ្តឹងលើការរៀបចំយោបល់ (ជាភាសាខ្មែរ) ហើយផ្ញើរយោបល់នោះទៅការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស | ថ្ងៃទី ៣០ វិច្ឆិកា ២០០៧ |
| ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស ទទួលបានយោបល់ដែលបកប្រែជាភាសាអង់គ្លេស | ថ្ងៃទី ០៤ ធ្នូ ២០០៧ |
| និវាសនដ្ឋានបេសកកម្មប្រចាំប្រទេសកម្ពុជា អាចចង់ធ្វើការពិភាក្សារបាយការណ៍ ជាមួយរដ្ឋាភិបាល | ចន្លោះ ថ្ងៃទី១៦ វិច្ឆិកា និង ថ្ងៃទី ៣០ វិច្ឆិកា ២០០៧ |
| និវាសនដ្ឋានបេសកកម្មប្រចាំប្រទេសកម្ពុជា ផ្តល់យោបល់លើរបាយការណ៍ | ថ្ងៃទី៣០ វិច្ឆិកា ២០០៧ |
| ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស ផ្តល់អនុសាសន៍ជូនប្រធានធនាគារអភិវឌ្ឍន៍អាស៊ីអំពី:<br>➢ ការសម្រេចចិត្តថាការបន្តដំណើរការពិគ្រោះយោបល់ត្រូវតាមគោលបំណង ឬក៏មិនស្របតាមគោលបំណង<br>➢ ប្រសិនបើស្របតាមគោលបំណង រៀបចំដាក់ចេញនូវវិធានសកម្មភាព ហើយផ្តល់យោបល់សម្រាប់វិធានសកម្មភាពនោះ ដែលត្រូវស្រង់ចេញពីរបាយការណ៍ត្រួតពិនិត្យ និងវាយតម្លៃ យោបល់របស់ដើមបណ្តឹង និង និវាសនដ្ឋានបេសកកម្មប្រចាំប្រទេសកម្ពុជា និង យោបល់របស់ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស | ត្រឹមសប្តាហ៍ទី១ ខែធ្នូ ឆ្នាំ២០០៧ |
| ការិយាល័យអ្នកសម្របសម្រួលគម្រោងពិសេស ឬ អ្នកសម្របសម្រួលផ្សេងទៀត ជួយសម្របសម្រួលលើការរៀបចំដាក់ចេញនូវវិធានសកម្មភាព :<br>➢ គ្រប់ភាគីពាក់ព័ន្ធទាំងអស់ (ដូចជា និវាសនដ្ឋានបេសកកម្មប្រចាំប្រទេសកម្ពុជា រដ្ឋាភិបាល ដើមបណ្តឹង អង្គការមិនមែនរដ្ឋាភិបាលនានា)<br>➢ ការពិគ្រោះយោបល់ ឬ កិច្ចប្រជុំមួយចំនួនជាមួយអ្នកពាក់ព័ន្ធ ក្រោមការសម្របសម្រួលដែលមានគោលបំណង ដើម្បីស្វែងរកការឯកភាពគ្នាលើវិធានការសកម្មភាព និងលើរបៀបអនុវត្តវិធានសកម្មភាពនោះ | សប្តាហ៍ទី១ ខែធ្នូ ឆ្នាំ២០០៧ |

**ជំហានទី ៧ : ការអនុវត្តវិធានសកម្មភាព** - ក្របខ័ណ្ឌពេលវេលាអនុវត្ត អាស្រ័យលើសកម្មភាពដែលបានឯកភាពគ្នា និងដែលត្រូវឯកភាពដោយអ្នកពាក់ព័ន្ធ

**ជំហានទី ៨ :** ការបញ្ចប់ដំណើរការពិគ្រោះយោបល់

## គំរូនៃវិធានផ្ទៃក្នុងសម្រាប់ការប្រជុំពិភាក្សា

រាល់ភាគីទាំងអស់ដែលចូលរួមក្នុងដំណើរការប្រជុំពិភាក្សានេះ នឹងគោរពអនុវត្តតាមវិធានផ្ទៃក្នុង ដូចខាងក្រោម[១] :

១. មិនអនុញ្ញាតឱ្យអ្នកសារព័ត៌មានចូលរួមក្នុងកិច្ចប្រជុំ ហើយមិនឱ្យមានអ្នកពាក់ព័ន្ធណាមួយប្រាប់ព័ត៌មានដល់អ្នកសារព័ត៌មាន មុនពេលឈានដល់កិច្ចព្រមព្រៀងឡើយ ។

២. អ្នកចូលរួមក្នុងដំណើរការពិគ្រោះយោបល់ គឺត្រូវមានតែអ្នកដែលមានការឯកភាពគ្នាជាមុន ។

៣. នៅពេលបញ្ចេញមតិ ត្រូវបញ្ចេញមតិម្តងម្នាក់ ហើយមិនត្រូវរំខានដល់អ្នកដទៃ ដែលកំពុងបញ្ចេញមតិឡើយ ។

៤. អ្នកចូលរួមម្នាក់ៗត្រូវរង់ចាំ ដល់មានការផ្តល់សញ្ញាពីអ្នកសម្របសម្រួល មុនធ្វើការបញ្ចេញមតិ ។

៥. មនុស្សម្នាក់ៗត្រូវបង្ហាញពីទស្សនៈរបស់អង្គការ និងស្ថាប័នរបស់ខ្លួន ជាជាងការនិយាយជំនួសអ្នកដទៃ ។

៦. ដោយពិចារណាពីពេលវេលាមានកំណត់ ហើយដើម្បីធានាឱ្យមានការចូលរួមជាអតិបរិមា អ្នកចូលរួមត្រូវប្តេជ្ញាលើកយោបល់ឱ្យខ្លី ហើយត្រូវចំណុច ។

៧. អ្នកចូលរួមម្នាក់ៗត្រូវជៀសវាងការបញ្ចេញមតិវាយប្រហារលើបុគ្គល ហើយត្រូវខិតខំគោរពតាមរបៀបវារៈ និងជៀសវាងការបញ្ចេញមតិបែបអួតអាង និងការបញ្ចេញមតិមិនត្រូវចំណុច ដោយត្រូវធ្វើយ៉ាងណាឱ្យមានការផ្តោតអារម្មណ៍លើការពិភាក្សា និងមានលក្ខណៈស្ថាបនា ។

៨. ក្រុមអ្នកសម្របសម្រួលនឹងជួយអនុវត្តវិធានផ្ទៃក្នុង បន្ទាប់ពីវិធាននោះ ត្រូវបានទទួលយល់ព្រមពីអ្នកចូលរួមទាំងអស់គ្នា ។ ក្រុមសម្របសម្រួល នឹងអនុវត្តដោយប្រកាន់ខ្ជាប់នូវអព្យាក្រឹតភាព និងភាពឥតលំអៀង ។

៩. ក្រោយពេលកិច្ចប្រជុំជាបន្តបន្ទាប់ ឬ កិច្ចប្រជុំដោយឡែកណាមួយ អ្នកសម្របសម្រួល នឹងសរសេរ ហើយចែកចាយរបាយការណ៍ស្តីពីលទ្ធផលនៃកិច្ចប្រជុំ ជាភាសាអង់គ្លេស និងភាសាខ្មែរ ជូនគ្រប់ភាគីទាំងអស់ ។

---

[១] អ្នកពាក់ព័ន្ធទាំងអស់ ជាអ្នកសម្រេចថា វិធានណាខ្លះ ក្នុងចំណោមវិធានគំរូនេះ ដែលពួកខ្លួនចង់យកមកអនុវត្ត នៅក្នុងដំណើរការពិភាក្សា ហើយក៏អាចលើកយោបល់កែប្រែ និង បន្ថែមវិធានផ្សេងៗទៀតដែលយល់ថាចាំបាច់ ។ វិធានផ្ទៃក្នុង មិនត្រូវមានលក្ខណៈជាពុម្ពទេ មានន័យថា ប្រសិនបើនៅក្នុងដំណើការពិគ្រោះយោបល់ អ្នកសម្របសម្រួល ឬ អ្នកចូលរួមទាំងឡាយ ពិចារណាឃើញថា មានការចាំបាច់ក្នុងការបន្ថែម ឬ កែប្រែវិធាន ពួកគេអាចកែប្រែ ឬ បន្ថែមបាន ឱ្យតែទាំងអស់គ្នាមានការឯកភាព ។